# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

# CAMBODIAN CENTER FOR HUMAN RIGHTS

## លទ្ធិប្រជាធិបតេយ្យ DEMOCRACY

## សិទ្ធិមនុស្ស HUMAN RIGHTS

## ពលរដ្ឋវិជ្ជា CIVIC EDUCATION


ស្រាវជ្រាវ និង ចងក្រងដោយ

លោក គីម សុខា និង លោក គៀត សុគន្ធ

ជំនួយការរៀបចំ

លោក ស៊ុយ ម៉ៅឈិន    លោក ជួន យុខ



ឧបត្ថម្ភថវិកាដោយ USAID IRI

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

បច្ចុប្បន្នមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានការិយាល័យចំនួន ៨កន្លែង

ដូចបានរាយអាស័យដ្ឋាន នៅសន្លឹកជាប់ក្របខាងមុខ និង ខាងក្រោយ :

- **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ការិយាល័យកណ្តាល**
  - អាស័យដ្ឋានផ្ទះលេខ ៤២ ផ្លូវលេខ ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
  - ទូរស័ព្ទ និង ទូរសារ: (៨៨៥-២៣) ២១៨ ៨៤៣
- **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តំបន់ ១ ខេត្តតាកែវ**
  - អាស័យដ្ឋាន ភូមិផ្សារតាកោរ ឃុំរការក្នុង ស្រុកដូនកែវ ខេត្តតាកែវ
  - ទូរស័ព្ទ និង ទូរសារ: (៨៥៥-៣២) ៩៣១ ៤១៤.
  - ទូរស័ព្ទដៃ: ០១២ ៦៥៥ ៤០៨
- **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តំបន់ ២ ខេត្តកំពង់ស្ពឺ**
  - អាស័យដ្ឋានដីឡូត៍លេខ $A_4$, ០៧៧៥ ក្រុមទី១ ភូមិមុខខេត្ត ឃុំរការធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ។
  - ទូរស័ព្ទ និង ទូរសារ: (៨៥៥-២៥ ) ៩៨៧ ៣៩៥. ទូរស័ព្ទដៃ: ០១២ ៩៩៨ ០៦៨
- **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តំបន់៣ ខេត្តព្រៃវែង**
  - អាស័យដ្ឋានផ្ទះលេខ២៩៦ ភូមិព្រែកខ្សាយ ឃុំព្រែកខ្សាយ"ក" ស្រុកពាមរក៍ ខេត្តព្រៃវែង។
  - ទូរស័ព្ទ និង ទូរសារ: (៨៥៥-៤៣) ៧៥០ ១២៧.
  - ទូរស័ព្ទដៃ: ០១២ ៩៩៨ ០៧២

លទ្ធិប្រជាធិបតេយ្យ DEMOCRACY

សិទ្ធិមនុស្ស HUMAN RIGHTS

ពលរដ្ឋវិជ្ជា CIVIC EDUCATION

# មាតិកា


i. អារម្ភកថា ........................................ ១

ii. គោលដៅរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ........................................ ៣

iii. លទ្ធិប្រជាធិបតេយ្យ ........................................ ៥

I. សេចក្តីផ្តើម ........................................ ៥

II. និយមន័យ ........................................ ៦

■ សារៈសំខាន់ប្រជាធិបតេយ្យ ........................................ ៨

III. គោលការណ៍សំខាន់ៗរបស់លទ្ធិប្រជាធិបតេយ្យ ........................................ ៩

■ ការប្រៀបធៀបរបបនយោបាយ ........................................ ១៦

iv. សិទ្ធិមនុស្ស ........................................ ១៨

I. សេចក្តីផ្តើម ........................................ ១៨

II. និយមន័យ ........................................ ២០

III. សារៈសំខាន់ ........................................ ២១

IV. សិទ្ធិផ្សេងៗ ........................................ ២១

V. សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ........................................ ២៣

១.សិទ្ធិពលរដ្ឋ ........................................ ២៣

២. សិទ្ធិនយោបាយ ........................................ ២៥

VI. ការអនុវត្តន៍សិទ្ធិ ........................................ ២៨

v. រដ្ឋធម្មនុញ្ញជំពូកទី៣ (សិទ្ធិ និង ករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ) ....... ៣១

vi.ពលរដ្ឋវិជ្ជា ........................................ ៣៦

I. សេចក្តីផ្តើម ........................................................................ ៣៦
II. និយមន័យ ........................................................................ ៣៦
១. ពលរដ្ឋ ........................................................................ ៣៧
២. រដ្ឋ ឬប្រទេស ........................................................................ ៣៨
៣. អត្តសញ្ញាណជាតិ ........................................................................ ៣៨
III. ការគ្រប់គ្រងរដ្ឋ ........................................................................ ៣៩
១. របបប្រជាធិបតេយ្យសេរី ........................................................................ ៣៩
២. របបផ្តាច់ការ ........................................................................ ៤០
IV. ស្ថាប័នជាតិធំៗ ........................................................................ ៤១
១. ស្ថាប័ននីតិបញ្ញត្តិ ........................................................................ ៤១
២. ស្ថាប័ននីតិប្រតិបត្តិ ........................................................................ ៤៣
៣. ស្ថាប័នតុលាការ ឬអំណាចតុលាការ ........................................................................ ៤៥
V. អំណាចផ្សេងៗ ........................................................................ ៤៧
១. ព្រះមហាក្សត្រ ........................................................................ ៤៧
២. ក្រុមប្រឹក្សាធម្មនុញ្ញ ........................................................................ ៤៨
៣. សមាជជាតិ ........................................................................ ៤៨
៤. ប្រព័ន្ធផ្សព្វផ្សាយ ........................................................................ ៤៩
៥. សង្គមស៊ីវិល ........................................................................ ៤៩
៦. គណបក្សនយោបាយ ........................................................................ ៤៩
VI. សេចក្តីសន្និដ្ឋាន ........................................................................ ៥០
viii. គំរូពាក្យបណ្តឹង ........................................................................ ៥៣

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់ការគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យ អស់ជាច្រើនទសវត្សរ៍កន្លងមកហើយ។ ទ្រឹស្តីប្រជាធិបតេយ្យនេះ គេឃើញមានចែងនៅក្នុងគម្ពីរព្រះពុទ្ធសាសនាជាច្រើនអន្លើ។ ប៉ុន្តែការអនុវត្តន៍ទ្រឹស្តីនេះមិនបាននាំមកនូវភាពសុខសាន្តជូនដល់ប្រជាពលរដ្ឋខ្មែរឡើយដោយអ្នកខ្លះយល់ឃើញថា គួរអនុវត្តបែបនេះ ហើយអ្នកខ្លះថា គួរអនុវត្តបែបនោះដែលបង្កឱ្យប្រទេសជាតិធ្លាក់ចុះក្នុងភាពខ្លោចផ្សា បែកបាក់សង្គមជាតិនឹងអាចឈានទៅរកការបាត់បង់ឈ្មោះពីពិភពលោក។

ក្រោយកិច្ចព្រមព្រៀងនៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ នាទីក្រុងប៉ារីសដែលនាំមកជូនប្រជាជាតិខ្មែរនូវរបបគ្រប់គ្រងបែបប្រជាធិបតេយ្យសេរីពហុបក្សគួរណាស់តែប្រជាពលរដ្ឋយើងទទួលបាននូវសេចក្តីសុខសម្បូរណ៏សប្បាយ ដូចប្រទេសប្រជាធិបតេយ្យនានាក្នុងលោក។ ប៉ុន្តែរយៈពេលជិត ១០ ឆ្នាំកន្លងមកនេះបែរជាពលរដ្ឋ និង ប្រទេសនៅតែបន្តការរងទុក្ខសោកមិនឈប់ឈរ។ ប្រជាពលរដ្ឋខ្មែរនៅតែមិនទាន់យល់ថា ខ្លួនជាម្ចាស់អំណាចម្ចាស់ទឹកដី និង ម្ចាស់ជោគវាសនារបស់ខ្លួន។ រីឯមន្ត្រីរាជការ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់នៅតែយល់ថា ខ្លួនជាចៅហ្វាយប្រជាពលរដ្ឋនៅឡើយ។ ស្ថិតនៅចំពោះមុខស្ថានការបែបនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" ដែលមានលោក កឹម សុខា ជាស្ថាបនិក បានចាប់កំណើតឡើងកាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០២ និងបានចូលខ្លួនមករួមចំណែកក្នុងការផ្សព្វផ្សាយ និង អនុវត្តព្រមទាំងជួយជំរុញឱ្យប្រជាពលរដ្ឋខ្មែរទាំងអស់បានយល់ដឹង និង ចេះអនុវត្តនូវលទ្ធិប្រជាធិបតេយ្យពិតប្រាកដក្នុងបំណងធ្វើឱ្យមានការផ្លាស់ប្តូរនូវការគ្រប់គ្រងតាមមូលដ្ឋាន ដែលពុំទាន់បានយកចិត្តទុកដាក់ដល់

ជីវភាព សុខុមាលភាព សន្តិសុខ...។ល។ ចំពោះប្រជាពលរដ្ឋដោយលើកទឹកចិត្តអ្នកទាំងនោះតាមរយៈវគ្គបណ្តុះបណ្តាលនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យពិតប្រាកដដើម្បីឱ្យពួកគាត់បានប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញដែលចែងថា " **ប្រជាពលរដ្ឋជាម្ចាស់អំណាច ម្ចាស់ទឹកដី និង ម្ចាស់ជោគវាសនារបស់ខ្លួន** "។

ដោយសារបំណងប្រាថ្នាដ៏មុះមុតនេះ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាព្រមទាំងសហការីទាំងអស់បានខិតខំស្រាវជ្រាវប្រមូលនូវបណ្តាឯកសារនានាដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និង ពលរដ្ឋវិជ្ជា មកចងក្រងជាឯកសារនេះឡើងដែលមាន ៣ ប្រធានបទគឺ " **ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលរដ្ឋវិជ្ជា** "សំរាប់ជាឯកសារពិគ្រោះស្រាវជ្រាវ និង បណ្តុះបណ្តាលជូនចំពោះប្រជាពលរដ្ឋ សិស្ស និស្សិត ព្រះសង្ឃ មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធទុកជាពន្លឺមួយក្នុងការអនុវត្តន៍ ត្រួសត្រាយផ្លូវសំរាប់ការធ្វើសេចក្តីសំរេចចិត្តនានាក្នុងការដោះស្រាយជីវភាព និង ជ្រើសរើសអ្នកដឹកនាំល្អដែលចេះលើកស្ទួយជីវភាព និង ដឹងសុខទុក្ខប្រជាពលរដ្ឋទូទៅមិនរើសអើង។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសង្ឃឹម និង ជឿជាក់ថា មិត្តអ្នកអាននឹងផ្តល់នូវមតិរិះគន់ ស្ថាបនាលើចំណុចផ្គាំផ្គងនានាមកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាយើងខ្ញុំ ដើម្បីនឹងសម្រួលកែលំអនូវឯកសារនេះឱ្យកាន់តែមានខ្លឹមសារសមស្របទៅនឹងសភាពការណ៍ពិតនៃប្រទេសជាតិយើង។

**សូមអរព្រះគុណ!**

**សូមអរគុណ!**

# គោលដៅរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចាប់ផ្តើមការងាររបស់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២00២ មានទិសដៅលើកស្ទួយ និង ការពារសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដោយមិនប្រកាន់និន្នាការនយោបាយ ពូជសាសន៍ ភេទ ឬសាសនាឡើយ។ ដើម្បីសំរេចទិសដៅនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមានកម្មវិធីៈ

១. បណ្តុះបណ្តាលនូវលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលរដ្ឋវិជ្ជាជូនប្រជាពលរដ្ឋគ្រប់ស្រទាប់ក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋដែលមានចំណេះដឹងថ្នាក់មធ្យមតាមមូលដ្ឋាននានា ហើយលើកទឹកចិត្តឱ្យអ្នកទាំងនោះចេះ និង ហ៊ានអនុវត្តនូវសិទ្ធិរបស់ខ្លួន ព្រមទាំងជួយផ្សព្វផ្សាយបន្តជូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានជាមួយដើម្បីឱ្យអ្នកទាំងនោះក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរការគ្រប់គ្រងនៅទីកន្លែងដែលគាត់រស់នៅឱ្យមានអ្នកដឹកនាំល្អ និង មានជីវភាពកាន់តែឈានឡើងជាលំដាប់។

២. ការស៊ើបអង្កេត និង ឃ្លាំមើលបទរំលោភបំពានសិទ្ធិ ច្បាប់នានាពីសំណាក់អ្នកមានទ្រព្យ និង អំណាចមកលើប្រជាពលរដ្ឋ ជាពិសេសសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយក្នុងគោលបំណងជួយពួកគាត់ឱ្យចេះ ឱ្យមានជីវភាពសមរម្យ និង ហ៊ានតស៊ូប្រឆាំងដោយអហិង្សានូវការរំលោភបំពាននានាពីសំណាក់អ្នកមានអំណាច និង បក្សពួក។ ជាមួយនេះនឹងផ្តល់ជូនពួកគាត់ឱ្យចេះលើកគំនិតផ្តួចផ្តើមនានាក្នុងការអភិវឌ្ឍន៍មូលដ្ឋានខ្លួន ព្រមទាំងចេះដោះស្រាយរួមគ្នាប្រកបដោយស្មារតីសហប្រតិបត្តការនូវបញ្ហាដែលកើតមានក្នុងភូមិឃុំរបស់ពួកគាត់ជាមួយនឹងអាជ្ញាធរនៅទីនោះផង។

៣. ការផ្សព្វផ្សាយ និង អប់រំតាមវិទ្យុដែលជាកម្មវិធីមួយផ្ដល់ជូនប្រជាពលរដ្ឋនូវឱកាសសំរាប់សំដែងមតិក្ដីកង្វល់ផ្សេងៗទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ ដោយផ្ដល់ជូននូវនាទីច្បាប់ និង ការពិសោធន៍ផ្សេងៗទាក់ទងនឹងប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលរដ្ឋវិជ្ជាដែលប្រទេសប្រជាធិបតេយ្យ ហើយប្រជាពលរដ្ឋនានាបានទទួលទាំងធនធាន ទាំងចំណេះដឹងតាមរយៈគោលការណ៍ និង អ្នកដឹកនាំរួមទាំងការទទួលខុសត្រូវលើវាសនាខ្លួន និង ប្រទេសជាតិផង។

គោលដៅទាំងនោះ អាចនឹងសំរេចបាន អាស្រ័យដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ ព្រមទាំងសមត្ថកិច្ចគ្រប់លំដាប់រួមទាំងកងកំលាំងប្រដាប់អាវុធកាន់តែកុះករឡើងជាលំដាប់ ព្រោះថាអ្នកទាំងអស់ទោះមានមុខនាទីជាអ្វីក៏ដោយ គឺសុទ្ធតែជាប្រជាពលរដ្ឋដូចៗគ្នា ហើយមានករណីកិច្ច និង កាតព្វកិច្ចដូចៗគ្នាមានតម្លៃជាមនុស្សស្មើៗគ្នាដែរចំពោះជាតិមាតុភូមិរបស់ខ្លួន។

# លទ្ធិប្រជាធិបតេយ្យ

## I- សេចក្ដីផ្ដើម

នៅក្នុងពិភពលោកយើងនេះ មានការគ្រប់គ្រងប្រទេសតាមរបបនយោបាយប្លែកៗគ្នាដូចជា របបអនាធិបតេយ្យ របបកុម្មុយនីស្ត របបផ្ដាច់ការ និងរបបប្រជាធិបតេយ្យ។ ក្នុងចំណោមរបបនយោបាយទាំងនោះ មានតែរបបប្រជាធិបតេយ្យទេដែលមានការរីកសាយភាយកាន់តែច្រើនឡើងៗ ចំណែកឯរបបផ្សេងៗទៀតខាងលើនេះបានត្រូវរលំរលាយជាលំដាប់លំដោយទៅហើយ ទោះបីជាមេដឹកនាំក្នុងរបបទាំងនោះខិតខំពង្រឹងអំណាចយោធា លុយកាក់ច្រើនសន្ធឹកសន្ធាប់យ៉ាងណាក៏ដោយ។

*ឧទាហរណ៍:* របបកុម្មុយនីស្តតាមលទ្ធិម៉ាក់ឡេនីន និង លទ្ធិម៉ៅបានត្រូវថយចុះជាលំដាប់ របបផ្ដាច់ការរបស់លោក ម៉ាក់កូស្សនៅហ្វីលីពីនបានត្រូវរលំ របបផ្ដាច់ការរបស់លោក ស៊ូ ហារតូ នៅឥណ្ឌូណេស៊ីបានត្រូវរលំ របបផ្ដាច់ការរបស់ លោក មីឡូស្សូវិច នៅយូហ្គូស្លាវីបានត្រូវរលំ។

ម្យ៉ាងទៀត មានអ្នកដឹកនាំប្រទេស និង គណបក្សនយោបាយមួយចំនួនតែងតែប្រកាសថា របបរបស់ខ្លួន ឬគណបក្សរបស់ខ្លួនជារបបប្រជាធិបតេយ្យ ឬគណបក្សប្រជាធិបតេយ្យ។ ដូចជានៅកម្ពុជាយើង សូម្បីតែរបបប្រល័យពូជសាសន៍ប៉ុលពតក៏បានយកពាក្យប្រជាធិបតេយ្យមកប្រើដែរ។ រហូតដល់គេបានដាក់ឈ្មោះរបបនេះថា កម្ពុជាប្រជាធិបតេយ្យទៀតផង។ ដូច្នេះតើរបបប្រជាធិបតេយ្យពិតប្រាកដនោះមាន ន័យ មានសារៈសំខាន់ និង មានគោលការណ៍យ៉ាងណា?

## II. និយមន័យ

ក្នុងប្រវត្តិសាស្ត្រ ប្រជាធិបតេយ្យចាប់កំណើតមុនដំបូងបង្អស់នៅប្រទេសក្រិក ដោយទស្សនវិទូជាច្រើនរូបមានដូចជា លោកសូក្រាត ប្លាតុង........។ល ។ ពាក្យថា *"ប្រជាធិបតេយ្យ"* មកពីពាក្យក្រិកថា Demos ដែលមានន័យថា *"ប្រជាពលរដ្ឋ"* និង ពាក្យ Kratos មានន័យថា *"សិទ្ធិអំណាច"*។

- ប្រជាធិបតេយ្យ = ប្រជា + អធិបតេយ្យ = ប្រជាពលរដ្ឋជាធំ

- លទ្ធិប្រជាធិបតេយ្យ គឺជាលទ្ធិមួយដែលផ្តល់អំណាចជូនទៅប្រជាពលរដ្ឋ។

ឆ្លងតាមការអនុវត្តន៏កន្លងមក លទ្ធិប្រជាធិបតេយ្យមានពីរប្រភេទសំខាន់ៗគឺ:

- ប្រជាធិបតេយ្យដោយផ្ទាល់ មានន័យថាប្រជាពលរដ្ឋជាអ្នកគ្រប់គ្រងដឹកនាំរដ្ឋដោយផ្ទាល់លើកិច្ចការរដ្ឋបាល ការពារជាតិ អភិវឌ្ឍន៏ជាតិជាដើម។ ប្រជាធិបតេយ្យប្រភេទនេះត្រូវបានអនុវត្តមុនគេនៅក្នុងប្រទេសក្រិក ហើយបច្ចុប្បន្នប្រភេទនេះស្ទើរតែបាត់រូបរាងទៅហើយ។

- ប្រជាធិបតេយ្យតំណាង ឬប្រយោលមានន័យថា ប្រជាពលរដ្ឋជាអ្នកជ្រើសតាំងឡើងនូវតំណាងរបស់ខ្លួនដើម្បីឱ្យអ្នកទាំងនោះអនុវត្តនូវការគ្រប់គ្រងប្រទេសពីមួយថ្ងៃទៅមួយថ្ងៃ និង សំរេចទៅលើបញ្ហាសំខាន់ៗដូចជាការបង្កើតច្បាប់ និង អនុវត្តច្បាប់ហើយអ្នកតំណាងទាំងនោះត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋ។ នៅសម័យបោះឆ្នោតពលរដ្ឋអាចសម្តែងការយល់ព្រម ឬមិនយល់ព្រមរបស់ខ្លួនដោយធ្វើការបោះឆ្នោតឱ្យធ្វើតំណាងឬមិនបោះឆ្នោតឱ្យ។ ប្រជាធិបតេយ្យតំណាងនេះមានប្រជាធិបតេយ្យបែបសភា ប្រជាធិបតេយ្យបែបប្រធានាធិបតី និង ប្រជាធិបតេយ្យបែបចំរុះ។ ប្រភេទ

នៃប្រជាធិបតេយ្យទាំងនោះកំណត់យោងទៅលើទំនាក់ទំនងរវាងអំណាចនីតិបញ្ញត្តិ (តាក់តែងច្បាប់) និង អំណាចនីតិប្រតិបត្តិ (រដ្ឋាភិបាល) ដែលជាអ្នកអនុវត្តច្បាប់នោះ។

ដូច្នេះ លទ្ធិប្រជាធិបតេយ្យគឺជាទំរង់នៃរបបនយោបាយមួយសំរាប់គ្រប់គ្រងរដ្ឋ ឬប្រទេសដែលលើកយកប្រជាពលរដ្ឋជាធំ ជាម្ចាស់អំណាច និង ជាម្ចាស់វាសនាប្រទេស ជាតិ។

ដើម្បីធ្វើអោយសំរេចបានប្រជាពលរដ្ឋជាធំ ជាម្ចាស់អំណាច និង ជាម្ចាស់វាសនាប្រទេសជាតិនោះ នៅក្នុងរបបប្រជាធិបតេយ្យពិតប្រាកដ ការគ្រប់គ្រងរដ្ឋ ឬប្រទេសត្រូវមាន ÷

- រដ្ឋាភិបាលដែលជារបស់ប្រជាពលរដ្ឋ
- រដ្ឋាភិបាលដែលកើតចេញពីប្រជាពលរដ្ឋ
- រដ្ឋាភិបាលដែលធ្វើអ្វីៗដើម្បីប្រជាពលរដ្ឋ

**<u>រដ្ឋាភិបាលដែលជារបស់ប្រជាពលរដ្ឋ</u>** គឺរដ្ឋាភិបាលនោះមិនមែនជាកម្មសិទ្ធិរបស់បុគ្គលណា ឬរបស់មេដឹកនាំណា ឬរបស់គណបក្សនយោបាយណា ឬរបស់ក្រុមណានោះឡើយ ទោះបីគេតែងតែដាក់ងារថា រដ្ឋាភិបាលលោកនេះ រដ្ឋាភិបាលគណបក្សនោះក៏ដោយ។ ពោលគឺក្នុងរបបប្រជាធិបតេយ្យ រដ្ឋាភិបាលជាកម្មសិទ្ធិរបស់ប្រជា ពលរដ្ឋ។ បើរដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាលនោះធ្វើការល្អ មានកេរ្តិ៍ឈ្មោះល្អ មានកិត្តិយសល្អ គឺកេរ្តិ៍ឈ្មោះ និង កិត្តិយសនោះជារបស់ប្រទេសជាតិ តែផ្ទុយទៅវិញ បើរដ្ឋាភិបាល ឬអ្នកដឹកនាំរបស់រដ្ឋាភិបាលនោះធ្វើអំពើអាក្រក់ខូចកេរ្តិ៍ឈ្មោះ វាអាចនាំឱ្យប្រទេសជាតិនោះទទួលរងនូវភាពអាម៉ាស់ផងដែរ។

**<u>រដ្ឋាភិបាលដែលកើតចេញពីប្រជាពលរដ្ឋ</u>** មានន័យថារដ្ឋាភិបាលនោះត្រូវតែកើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌តាមឆន្ទៈពិតរបស់ប្រជាពលរដ្ឋ។ ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំក្នុងលទ្ធិប្រជាធិបតេយ្យមិនមែនជាការបោះ

នៃប្រជាធិបតេយ្យទាំងនោះកំណត់យោងទៅលើទំនាក់ទំនងរវាងអំណាចនីតិបញ្ញត្តិ (តាក់តែងច្បាប់) និង អំណាចនីតិប្រតិបត្តិ (រដ្ឋាភិបាល) ដែលជាអ្នកអនុវត្តច្បាប់នោះ ។

ដូច្នេះ លទ្ធិប្រជាធិបតេយ្យគឺជាទំរង់នៃរបបនយោបាយមួយសំរាប់គ្រប់គ្រងរដ្ឋ ឬប្រទេសដែលលើកយកប្រជាពលរដ្ឋជាធំ ជាម្ចាស់អំណាច និង ជាម្ចាស់វាសនាប្រទេស ជាតិ ។

ដើម្បីធ្វើអោយសំរេចបានប្រជាពលរដ្ឋជាធំ ជាម្ចាស់អំណាច និង ជាម្ចាស់វាសនាប្រទេសជាតិនោះ នៅក្នុងរបបប្រជាធិបតេយ្យពិតប្រាកដ ការគ្រប់គ្រងរដ្ឋ ឬប្រទេសត្រូវមាន ÷

- រដ្ឋាភិបាលដែលជារបស់ប្រជាពលរដ្ឋ
- រដ្ឋាភិបាលដែលកើតចេញពីប្រជាពលរដ្ឋ
- រដ្ឋាភិបាលដែលធ្វើអ្វីៗដើម្បីប្រជាពលរដ្ឋ

<u>**រដ្ឋាភិបាលដែលជារបស់ប្រជាពលរដ្ឋ**</u> គឺរដ្ឋាភិបាលនោះមិនមែនជាកម្មសិទ្ធិរបស់បុគ្គលណា ឬរបស់មេដឹកនាំណា ឬរបស់គណបក្សនយោបាយណា ឬរបស់ក្រុមណានោះឡើយ ទោះបីគេតែងតែដាក់ងារថា រដ្ឋាភិបាលលោកនេះ រដ្ឋាភិបាលគណបក្សនោះក៏ដោយ ។ ពោលគឺក្នុងរបបប្រជាធិបតេយ្យ រដ្ឋាភិបាលជាកម្មសិទ្ធិរបស់ប្រជា ពលរដ្ឋ ។ បើរដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាលនោះធ្វើការល្អ មានកេរ្តិ៍ឈ្មោះល្អ មានកិត្តិយសល្អ គឺកេរ្តិ៍ឈ្មោះ និង កិត្តិយសនោះជារបស់ប្រទេសជាតិ តែផ្ទុយទៅវិញ បើរដ្ឋាភិបាល ឬអ្នកដឹកនាំរបស់រដ្ឋាភិបាលនោះធ្វើអំពើអាក្រក់ខូចកេរ្តិ៍ឈ្មោះ វាអាចនាំឱ្យប្រទេសជាតិនោះទទួលរងនូវភាពអាម៉ាស់ផងដែរ ។

<u>**រដ្ឋាភិបាលដែលកើតចេញពីប្រជាពលរដ្ឋ**</u> មានន័យថារដ្ឋាភិបាលនោះត្រូវតែកើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌តាមឆន្ទៈពិតរបស់ប្រជាពលរដ្ឋ ។ ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំក្នុងលទ្ធិប្រជាធិបតេយ្យមិនមែនជាការបោះ

ឆ្នោតដោយបង្ខិតបង្ខំ គំរាមកំហែង ទិញទឹកចិត្ត លួចបន្លំ ឬលំអៀងនោះទេ។ម្យ៉ាងទៀតរដ្ឋាភិបាលប្រជាធិបតេយ្យមិនត្រូវកើតឡើងដោយការលើកបន្ទុបរបស់បុគ្គល ក្រុមបក្ស ឬបរទេសណា ឬក៏កើតឡើងដោយកំលាំងអាវុធ រថក្រោះ ឬរដ្ឋប្រហារឡើយ។

**<u>រដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ</u>** ជារដ្ឋាភិបាលដែលបានកើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ ហើយរដ្ឋាភិបាលនោះត្រូវធ្វើអ្វីៗអោយបានផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ដែលជាម្ចាស់អំណាចដោយមិនត្រូវរើសអើងប្រកាន់បក្សពួកឡើយ។ គណបក្ស ឬអ្នកដឹកនាំគណបក្សអាចធ្វើការដើម្បីប្រយោជន៍គណបក្សខ្លួននៅពេលខ្លួនមិនទាន់កាន់អំណាចតែប៉ុណ្ណោះ ក៏ប៉ុន្តែនៅពេលដែលខ្លួនឈ្នះឆ្នោតបានដឹកនាំរដ្ឋាភិបាល ត្រូវធ្វើការដើម្បីប្រជាពលរដ្ឋទូទៅមិនប្រកាន់ថា ប្រជាពលរដ្ឋមកពីគណបក្សណាឡើយ។ រដ្ឋាភិបាលប្រជាធិបតេយ្យមិនត្រូវធ្វើអ្វីតាម តែទំនើងចិត្តអ្នកដឹកនាំ ឬក្រុម ឬបក្សនោះទេ ទោះបីប្រជាពលរដ្ឋបានបោះឆ្នោតអោយខ្លួនជាអ្នកដឹកនាំក្នុងអាណត្តិនោះហើយក៏ដោយ។ មុននឹងសំរេចកិច្ចការធំៗរបស់ប្រទេសជាតិ និង ជាពិសេសសំរេចធ្វើអ្វីមួយដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រដ្ឋាភិបាលប្រជាធិបតេយ្យត្រូវតែបើកឱកាសឱ្យប្រជាពលរដ្ឋចូលរួមក្នុង ការសំរេចដោយតម្លាភាពផង។

**"រដ្ឋាភិបាលប្រជាធិបតេយ្យ គឺជាអ្នកបំរើប្រជាពលរដ្ឋ"**

## ■ <u>សារៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យ</u>

*១. ប្រជាពលរដ្ឋទូទៅទទួលបានផលប្រយោជន៍ ហើយប្រទេសជាតិក៏មានការរីកចំរើន។*

*២. ប្រជាពលរដ្ឋអាចជ្រើសរើស និងផ្លាស់ប្តូរអ្នកដឹកនាំតាមឆន្ទៈរបស់ខ្លួនដោយសន្តិវិធី។*

*៣. មានសន្តិភាព សន្តិសុខ ស្ថិរភាពពិតប្រាកដ។*

*៤. ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពទូលំទូលាយ។*

*៥. ជំរុញអោយមានអភិបាលកិច្ចល្អ មានតម្លាភាព និង អាចទប់ស្កាត់អំពើពុករលួយ ។*

## III. គោលការណ៍សំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យ

ប្រទេសដែលប្រកាន់នូវរបបប្រជាធិបតេយ្យពិតប្រាកដយ៉ាងហោចណាស់ក៏ត្រូវអនុវត្តនូវគោលការណ៍សំខាន់ៗ ដូចខាងក្រោមនេះដែរ:

### ១. ការគោរពសិទ្ធិមនុស្ស

សិទ្ធិមនុស្ស គឺជាសេចក្តីត្រូវការចាំបាច់របស់មនុស្សគ្រប់រូបដែលមានតាំងពីកំណើតដើម្បីទាមទារនូវអ្វីៗដែលធ្វើអោយមនុស្សរស់នៅប្រកបដោយគុណធម៌ និង សេចក្តីថ្លៃថ្នូរ ។

**ឧទាហរណ៍:** សិទ្ធិក្នុងការនិយាយស្តី (កើតមកស្រែកយំ) សិទ្ធិក្នុងការមើល (មានភ្នែកត្រូវបានឃើញ) សិទ្ធិក្នុងការស្តាប់ (មានត្រចៀកត្រូវបានឮ) សិទ្ធិក្នុងការគិតពិចារណា (មានខួរក្បាលត្រូវគិត) ។ល។ ដើម្បីអោយប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីសង្គមលុះត្រាណាតែប្រជាពលរដ្ឋមានអំណាច ដើម្បីឱ្យប្រជាពលរដ្ឋមានអំណាចលុះត្រាណាតែប្រជាពលរដ្ឋអាច និង ហ៊ានប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានទូលំទូលាយ ។

ដូច្នេះ សិទ្ធិជាប្រភពនៃអំណាច ហើយអំណាចរបស់ប្រជាពលរដ្ឋជាភាពរឹងមាំនៃលទ្ធិប្រជាធិបតេយ្យ ។ ប្រទេសប្រជាធិបតេយ្យត្រូវមានច្បាប់ ដើម្បីធានា ការពារសិទ្ធិប្រជាពលរដ្ឋ ហើយរដ្ឋាភិបាលត្រូវទទួលខុសត្រូវគោរពសិទ្ធិប្រជាពលរដ្ឋ ជាពិសេសសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។

**"សិទ្ធិនាំមកនូវអំណាច អំណាចនាំមកនូវផលប្រយោជន៍"**

** ***<u>សិទ្ធិសំខាន់ៗមាន</u>*** : សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលនូវអាហារ និង ជំរកសមរម្យ សិទ្ធិទទួលនូវការអប់រំ សិទ្ធិទទួលបាននូវសេរីភាពខាងជំនឿ និង មនសិការផ្ទាល់ខ្លួន

សេរីភាពក្នុងការបញ្ចេញមតិយោបល់ សិទ្ធិបង្កើត និង ចូលរួមក្នុងសមាគម ឬគណបក្សនយោបាយ សិទ្ធិបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោត សិទ្ធិទទួលនូវសន្តិសុខផ្ទាល់ខ្លួន សិទ្ធិទទួលនូវការការពារខាងផ្លូវច្បាប់ សិទ្ធិស្មើភាព គ្នារវាងបុរស និង ស្ត្រី.....។

**" ការពារសិទ្ធិ គឺការពារជីវិត "**

## ២. ការចូលរួមពីប្រជាពលរដ្ឋ

ប្រជាពលរដ្ឋក្នុងប្រទេសប្រជាធិបតេយ្យមិនត្រឹមតែបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្រជាពលរដ្ឋប៉ុណ្ណោះទេ សំខាន់ទៅទៀតប្រជាពលរដ្ឋត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សហគមន៍ ឬរបស់ជាតិរួមទាំងការតាក់តែងច្បាប់តាមការបញ្ចេញមតិយោបល់តាមរយៈតំណាងរាស្ត្រ ឬតាមរយៈសមាគម សហជីពជាដើម។ ប្រជាពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យអាចប្រមូលផ្តុំគ្នាជាសមាគម សហជីពបង្កើតជាអង្គការនានាក្នុងសង្គមស៊ីវិលដើម្បីបំរើផលប្រយោជន៍ណាមួយរបស់ប្រជាពលរដ្ឋក្នុង សហគមន៍របស់ខ្លួន។ នៅក្នុងប្រទេសណាដែលប្រជាពលរដ្ឋធ្វើមិនដឹងមិនឮ បណ្តោយអោយអ្នកដឹកនាំធ្វើនូវអ្វីៗតាមអំពើចិត្ត ប្រទេសជាតិនោះមិនអាចរីកចំរើនបានទេ ជាពិសេសប្រជាពលរដ្ឋនៅក្នុងប្រទេសនោះតែងតែមានភាពក្រីក្រទៀតផង។ ការចូលរួមពីប្រជាពលរដ្ឋគឺជាការផ្តល់ឱកាសឱ្យប្រជាពលរដ្ឋខ្លួនឯងគិតគូរ និង ប្រាប់ទៅរដ្ឋាភិបាលថាត្រូវធ្វើអ្វីខ្លះដើម្បីបានផលប្រយោជន៍ទៅប្រជាពលរដ្ឋ និង ធ្វើអ្វីខ្លះដែលប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ។

**" បើមានការចូលរួមពីប្រជាពលរដ្ឋកាន់តែច្រើន របបប្រជាធិបតេយ្យកាន់តែរឹងមាំ "**

## ៣. ប្រព័ន្ធនយោបាយពហុបក្ស

គណបក្សនយោបាយគឺជាក្រុមរបស់ប្រជាពលរដ្ឋ ក្នុងប្រទេសមួយដែលមានគំនិតនយោបាយដូចគ្នា ឬប្រហាក់ប្រហែលគ្នាបំផុតក្នុងការគិតគូររៀបចំ និង គ្រប់គ្រងប្រទេស

នោះទៅតាមកម្មវិធី ឬបន្ទាត់នយោបាយដែលក្រុមពលរដ្ឋក្នុងគណបក្សនោះសំរេចថា នឹងយកមកអនុវត្តនៅពេលដែលគណបក្សខ្លួនឈ្នះឆ្នោតកាន់អំណាចក្នុងរដ្ឋាភិបាល។ ដូចនេះដើម្បីបើកឱកាសឱ្យក្រុមពលរដ្ឋដែលមានគោលនយោបាយផ្សេងៗគ្នាមានសេរីភាព និងមានឱកាសក្នុងការលើកយកគំនិត ឬគោលនយោបាយរបស់ខ្លួនមកដាក់ជូនប្រជាពលរដ្ឋទូទៅដើម្បីសំរេចគាំទ្រ ឬមិនគាំទ្រនោះក្នុងប្រទេសប្រជាធិបតេយ្យ គេត្រូវអនុញ្ញាតឱ្យមានគណបក្ស ច្រើនលើសពីមួយ គណបក្សច្រើន ឬពហុបក្ស គឺដើម្បីឱ្យប្រជាពលរដ្ឋមានជំរើសមិនផ្តាច់មុខដែលជាកត្តាសំខាន់បំផុតឱ្យមេដឹកនាំនយោបាយ ឬគណបក្សនយោបាយទាំងឡាយខិតខំសិរិតសំរាំងខ្លួនឱ្យបានល្អប្រសើរ និង ដើម្បីប្រលងប្រជែងគ្នាបង្ហាញស្នាដៃក្នុងការបំរើប្រជាពលរដ្ឋ និង បំរើប្រទេសជាតិ។ ផ្ទុយទៅវិញ បើគ្រាន់តែបើកឱ្យមានបក្សច្រើនហើយការជាក់ស្តែងអំណាចស្ថិតនៅលើតែបក្សមួយដដែលក៏មិនពិតថា ជាប្រទេសប្រជាធិបតេយ្យដែរ។ គណបក្សនយោបាយនីមួយៗនោះក៏ត្រូវមានប្រជាធិបតេយ្យក្នុងបក្សខ្លួនដែរ ពោលគឺគណបក្សជារបស់សមាជិកគណបក្សទាំងអស់គ្នាមិនមែនជាគណបក្សរបស់ប្រធានគណបក្សតែឯងឡើយ។

**"ប្រព័ន្ធនយោបាយពហុបក្សនាំមកនូវ ផលប្រយោជន៍កាន់តែច្រើនជូនប្រជាពលរដ្ឋ"**

## ៤. នីតិរដ្ឋ

នីតិរដ្ឋ គឺជាការគ្រប់គ្រងនៃច្បាប់។ ប្រទេសមួយដែលហៅថានីតិរដ្ឋគឺជាប្រទេសមួយដែលមានច្បាប់ គោរពច្បាប់ និង អនុវត្តច្បាប់ដោយគតិយុត្តិធម៌។ ច្បាប់ដែលល្អគឺជាច្បាប់ដែលបំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ដូច្នេះអ្នកធ្វើច្បាប់ត្រូវព្យាយាមធ្វើយ៉ាងណាអោយស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ។ ការគ្រប់គ្រងមួយប្រកបដោយនីតិរដ្ឋគឺជាការគ្រប់គ្រងមួយដែលយកច្បាប់ជាធំ។ ការគ្រប់គ្រងនេះមានន័យថា បុគ្គលគ្រប់រូប

ទោះមានឋានៈ វណ្ណៈខ្ពស់ដល់កំរិតណាមានលុយកាក់ច្រើនប៉ុណ្ណាក៏ដោយ ក៏ត្រូវតែគោរពច្បាប់ និង ស្ថិតនៅក្រោមច្បាប់ទាំងអស់គ្នា។

គ្រប់ស្ថាប័នរដ្ឋទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់ ការអនុវត្តន៍ច្បាប់ដោយមន្ត្រីរាជការក្នុងរដ្ឋាភិបាល ឬតុលាការត្រូវធ្វើឡើងប្រកបដោយគតិយុត្តិធម៌ ពោលគឺមិនត្រូវយកច្បាប់ទៅប្រើដោយទាញយឺតដូចកៅស៊ូតំរូវតាមផលប្រយោជន៍របស់ខ្លួន ឬបក្សពួកខ្លួនឡើយ។

**"ការគោរពច្បាប់ គឺជួយពង្រឹងសិទ្ធិឱ្យកាន់តែមានរស្មីភ្លឺថ្លា"**

## ៥. រដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវ និង មានអភិបាលកិច្ចល្អ

រដ្ឋាភិបាលប្រជាធិបតេយ្យត្រូវតែទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋរបស់ខ្លួន និង ចំពោះមុខជាតិនូវអ្វីដែលមានការធានាដោយច្បាប់ដែលប៉ះពាល់ដល់ប្រយោជន៍ជាតិ ប៉ះពាល់ដល់ប្រជាពលរដ្ឋ និង នូវអ្វីដែលរដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាលនោះបានសន្យា។ រដ្ឋាភិបាល ឬអ្នកដឹកនាំប្រទេសប្រជាធិបតេយ្យត្រូវក្លាហានហ៊ានចុះចេញពីតំណែងមុនអាណត្តិនៅពេលណាដែលប្រទេសជាតិ ឬប្រជាពលរដ្ឋខ្លួនធ្លាក់ក្នុងវិបត្តិណាមួយដោយសារខ្លួនអសមត្ថភាពក្នុងការដឹកនាំ។ លើសពីនេះទៅទៀត រដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាលត្រូវទទួលខុសត្រូវដាច់ខាតនូវអ្វីដែលខ្លួន បានអនុវត្តផ្ទុយពីច្បាប់ ឬផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ។ ក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋអាចចោទប្រកាន់ ឬប្តឹងរដ្ឋាភិបាល ឬអ្នកដឹកនាំទៅតុលាការបាន ហើយទាំងរដ្ឋាភិបាល ទាំងអ្នកដឹកនាំក៏ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដែរ។

ទន្ទឹមនឹងការទទួលខុសត្រូវខាងលើនេះ រដ្ឋាភិបាលប្រជាធិបតេយ្យត្រូវមានអភិបាលកិច្ចល្អ តម្លាភាពល្អ និង ចាត់ចែងការងាររបស់ខ្លួនបានត្រឹមត្រូវតាមច្បាប់ជាតិ និង

អន្តរជាតិ។ រដ្ឋាភិបាលត្រូវផ្សព្វផ្សាយពត៌មាន និង ឯកសារផ្សេងៗស្តីពីសកម្មភាពរបស់ខ្លួនអោយប្រជាពលរដ្ឋបានដឹងជាទូទៅ លើកលែងតែឯកសារ ឬពត៌មានណាដែលប៉ះពាល់ដល់សន្តិសុខជាតិ ហើយក៏ត្រូវទទួលស្គាល់កំហុស និង ទទួលយកនូវការកែលំអពីប្រជាពលរដ្ឋដើម្បីធ្វើអោយមានការជឿជាក់លើការដឹកនាំរបស់ខ្លួន។

- *ឧទាហរណ៍ :* ការបាត់បង់ទឹកដី ការបំផ្លិចបំផ្លាញធនធានធម្មជាតិ ភាពក្រីក្ររបស់ប្រជាពលរដ្ឋ អសន្តិសុខ អំពើពុករលួយ.....។

## ៦. តុល្យភាពរវាងអំណាចទាំងបី (នីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការ)

យន្តការសំខាន់បំផុតបីសំរាប់ដំណើរការគ្រប់គ្រងរដ្ឋក្នុងប្រទេសប្រជាធិបតេយ្យ គឺស្ថាប័ននីតិបញ្ញត្តិ (សភា) ស្ថាប័ននីតិប្រតិបត្តិ (រដ្ឋាភិបាល) និង ស្ថាប័នតុលាការ។ ដើម្បីឱ្យអំណាចទាំងបីនេះបំរើប្រយោជន៍ពិតប្រាកដសំរាប់ប្រទេស និង សំរាប់ប្រជាពលរដ្ឋស្របតាមគោលការណ៍ប្រជាធិបតេយ្យដែលប្រជាពលរដ្ឋជាម្ចាស់អំណាចលុះត្រាស្ថាប័នទាំងបីនេះបែងចែកអំណាចឱ្យដាច់ពីគ្នាមានតុល្យភាពរវាងអំណាចនីមួយៗ ជាពិសេសត្រូវមានប្រព័ន្ធតុលាការមួយឯករាជ។

សភាប្រជាធិបតេយ្យ គឺជាតំណាងពិតប្រាកដរបស់ប្រជាពលរដ្ឋមិនមែនគ្រាន់តែជាតំណាងខ្លួនឯង ឬគ្រាន់តែជាតំណាងគណបក្សខ្លួនប៉ុណ្ណោះទេ ពេលធ្វើច្បាប់ ឬមុននឹងអនុម័តអ្វីមួយដែលជាបញ្ហាធំៗរបស់ប្រទេសជាតិ ឬបញ្ហាដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ អ្នកតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាត្រូវតែស្តាបស្ទង់យោបល់ប្រជាពលរដ្ឋនៅតាមមណ្ឌល។ លើសពីនេះទៅទៀត សមាជិកសភាត្រូវតែមកដល់មណ្ឌលខ្លួនជាទៀងទាត់ដើម្បីស្វែងយល់អំពីបញ្ហា កង្វល់របស់ម្ចាស់ឆ្នោត ហើយលើកយកបញ្ហាទាំងនោះទៅធ្វើអន្តរាគមន៍ដើម្បីជួយដោះស្រាយ។

ចំពោះរដ្ឋាភិបាលដែលជាស្ថាប័ននីតិប្រតិបត្តិ ឬអនុវត្តវិញត្រូវតែមានការទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋដោយផ្ទាល់ ឬតាមរយៈសភាផ្ទាល់ ហើយមិនត្រូវសម្រេចកិច្ចការធំរបស់ជាតិ របស់ប្រជាពលរដ្ឋដោយគ្មានការសំរេចយល់ព្រមពីសភាឡើយ។ ជាពិសេសគេសង្កេតឃើញនៅក្នុងប្រទេសមួយចំនួន រដ្ឋាភិបាលច្រើនតែប្រើអំណាចរបស់ខ្លួនរំលោភទៅលើអំណាចសភា និង តុលាការ។

ឯតុលាការដែលត្រូវមានឯករាជភាពនោះមិនមែនមានន័យថា ចៅក្រម ព្រះរាជអាជ្ញា និង មន្ត្រីតុលាការទាំងនោះធ្វើអ្វីស្រេចតែចិត្តខ្លួនដោយលំអៀងដោយពុករលួយ ឬដោយបក្សពួកនោះទេ។ ឯករាជភាពរបស់តុលាការគឺ ឯករាជ្យពីការគំរាមកំហែងរបស់អ្នកមានអំណាច ឯករាជ្យពីបក្សពួក ឬគណបក្សនយោបាយ ឯករាជ្យពីការទិញដោយទឹកលុយ ប៉ុន្តែត្រូវធ្វើតាមច្បាប់ គោរពច្បាប់ អនុវត្តច្បាប់ឱ្យបានយុត្តិធម៌ឥតលំអៀង។

**"អតុល្យភាព រវាងអំណាចទាំងបី គឺធ្វើឱ្យលទ្ធិប្រជាធិបតេយ្យច្របូកច្របល់"**

## ៧. រដ្ឋបាល និង កំលាំងប្រដាប់អាវុធអព្យាក្រឹត

គឺជាការចាំបាច់ណាស់ដើម្បីអាចអនុវត្តលទ្ធិប្រជាធិបតេយ្យបានលុះត្រាតែរដ្ឋបាលគ្រប់ជាន់ថ្នាក់ និង កំលាំងប្រដាប់អាវុធដូចជាអាជ្ញាធរថ្នាក់លើ និង មូលដ្ឋាន ប៉ូលីស ទាហាន ប៉េអឹមជាដើម ត្រូវបំពេញការងារដោយអព្យាក្រឹត្យ។ ជាការពិតណាស់បុគ្គលដែលបំរើក្នុងស្ថាប័នរដ្ឋបាល ឬកំលាំងប្រដាប់អាវុធនោះក៏ជាពលរដ្ឋដែរហើយក៏មានសិទ្ធិក្នុងការចូលជាសមាជិក ឬគាំទ្រគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត អាចសំដែងមតិតាមរយៈការបោះឆ្នោតជ្រើសរើសគណបក្សណាមួយ ឬ បុគ្គលណាមួយ ក៏ប៉ុន្តែបុគ្គលជាអ្នកកាន់ការងាររដ្ឋបាល ឬជាកងកំលាំងប្រដាប់អាវុធ មិនត្រូវយកតួនាទី មុខតំណែង ឋានៈរបស់ខ្លួនទៅបំរើតែគណបក្សណាមួយនោះទេ គឺត្រូវបំរើប្រជាពលរដ្ឋទូទៅដោយមិនគិតពីនិន្នាការនយោបាយឡើយ។ ជាពិសេសទៅទៀតគេមិនត្រូវយក

ទ្រព្យសម្បត្តិសំភារៈ ថវិការដ្ឋទៅបំរើឱ្យគណបក្សដែលគេគាំទ្រនោះទេ។ ការយកតួនាទីមុខតំណែងទៅប្រើជាអំណាចដើម្បីឱ្យគេផ្តល់សគុណឱ្យខ្លួនគឺជាអំពើពុករលួយ ហើយការយកលុយកាក់ សំភារៈដែលបានមកពីអំពើនេះទៅសំរាប់ខ្លួន ក្រុមខ្លួន ឬបក្សខ្លួនគឺជាអ្នកដឹកនាំផ្តាច់ការ។

**"រដ្ឋបាល និង កម្លាំងប្រដាប់អាវុធ ជារបស់រដ្ឋាភិបាល រីឯរដ្ឋាភិបាល គឺជារបស់ប្រជាពលរដ្ឋ ដូច្នេះរដ្ឋបាល និង កម្លាំងប្រដាប់អាវុធ គឺជារបស់ប្រជាពលរដ្ឋដែរហើយត្រូវធ្វើការបំរើប្រជាពលរដ្ឋដោយឥតរើសមុខ"**

## ៨. សេដ្ឋកិច្ចផ្សារសេរី

សេដ្ឋកិច្ចផ្សារសេរី គឺជាប្រព័ន្ធសេដ្ឋកិច្ចដែលផ្ទុយពីសេដ្ឋកិច្ចប្រមូលផ្តុំ ឬសេដ្ឋកិច្ចផ្តាច់មុខ។ ដើម្បីឱ្យផលប្រយោជន៍សេដ្ឋកិច្ចបានទៅប្រជាពលរដ្ឋផង បានទៅប្រទេសជាតិផង និង អាចឱ្យមានការរីកចំរើនផ្នែកសេដ្ឋកិច្ចផង ប្រទេសប្រជាធិបតេយ្យត្រូវបើកឱ្យមានការប្រកួតប្រជែងក្នុងការលក់ ទិញ និង ជួលឱ្យមានលក្ខណៈតម្លាភាពជៀសវាងការកាន់កាប់ផ្តាច់មុខ។ សេដ្ឋកិច្ចផ្សារសេរីមិនមែនមានន័យថា ឱ្យអ្នករកស៊ីធ្វើអ្វីតាមទំនើងចិត្ត និង មិនមែនបើកដៃឱ្យរដ្ឋាភិបាល ឬសមត្ថកិច្ចនានាមានឱកាសដើម្បីប្រព្រឹត្តអំពើពុករលួយដើម្បីបក្សពួកនោះទេ។ សេដ្ឋកិច្ចផ្សារសេរី គឺជាសេដ្ឋកិច្ចដែលមានតម្លាភាព និង មានគុណភាព។

## ៩. ការបោះឆ្នោតដោយសេរីត្រឹមត្រូវ យុត្តិធម៌ និង ទៀងទាត់

ការបោះឆ្នោតគឺជាកត្តាសំខាន់បំផុតសំរាប់បើកផ្លូវឱ្យលទ្ធិប្រជាធិបតេយ្យ អាចអនុវត្តបាននៅក្នុងសហគមន៍ ឬប្រទេសនីមួយៗ។ ក៏ប៉ុន្តែក្នុងរបបដឹកនាំខ្លះមានព្រឹត្តិការណ៍បោះឆ្នោតដែរ តែផ្ទុយទៅវិញបើការបោះឆ្នោតនោះគ្រាន់តែជាឡប់ឡែមិនមានលក្ខណៈសេរី មិន

ត្រឹមត្រូវមិនយុត្តិធម៌ ឬមិនទៀងទាត់ពេលវេលា ក៏មិនអាចហៅថាការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ និង មិនអាចអោយលទ្ធិប្រជាធិបតេយ្យដំណើរការបានដែរ ។

- **ការបោះឆ្នោតដោយសេរី** មានន័យថាប្រជាពលរដ្ឋអាចសំរេចចិត្តជ្រើសរើសអ្នកដឹកនាំ ឬសំរេចចិត្តលើកិច្ចការអ្វីមួយទៅតាមឆន្ទៈរបស់ខ្លួនដោយប្រើសិទ្ធិតាមរយៈសន្លឹកឆ្នោតដោយគ្មានការបង្ខិតបង្ខំ គំរាមកំហែង បំភិតបំភ័យ ឬរាំងរាតាមរូបភាពផ្សេងៗ ។

- **ការបោះឆ្នោតដោយត្រឹមត្រូវ** មានន័យថា មិនមានការទិញដូរ មិនកេងបន្លំ ឬមិនលួចសន្លឹកឆ្នោតទោះជាតាមរូបភាពណាក៏ដោយ ។

- **ការបោះឆ្នោតដោយយុត្តិធម៌** មានន័យថា មិនលំអៀងទៅលើគណបក្សនយោបាយណាមួយ ជាពិសេសអាជ្ញាធររៀបចំការបោះឆ្នោតដូចជាគណកម្មការជាតិរៀបចំការបោះឆ្នោតត្រូវអព្យាក្រឹតជាដាច់ខាត គ្រប់គណបក្ស និង បេក្ខជនទាំងអស់ត្រូវទទួលបាននូវភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមធ្យោបាយ និង ទីកន្លែងសាធារណៈ របស់រដ្ឋ ។

- **ការបោះឆ្នោតដោយទៀងទាត់** មានន័យថា ពេលវេលានៃការបោះឆ្នោតត្រូវតែធ្វើទៅតាមកាលកំណត់ មិនត្រូវពន្យាពេលហួសអាណត្តិដោយយកលេសផ្សេងៗនោះទេលើកលែងតែមានសង្គ្រាមដែលបណ្តាលអោយមានការរាំងស្ទះដល់ដំណើរការរៀបចំការ បោះឆ្នោត ។

បើការបោះឆ្នោតមិនសេរី មិនត្រឹមត្រូវ និង មិនយុត្តិធម៌ទេ រដ្ឋសភា រដ្ឋាភិបាលដែលកើតឡើងដោយការបោះឆ្នោតនោះ មិនអាចជាតំណាងឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋដែរ ។

## * * ការប្រៀបធៀបរបបនយោបាយ

ដើម្បីងាយស្រួលក្នុងការប្រៀបធៀប និង ការវាយតំលៃថា តើរបបគ្រប់គ្រងប្រទេសនីមួយៗជារបបអ្វីនោះ យើងអាចពិនិត្យលើតារាងសង្ខេបដែលមានតារាងប្រៀប

ធៀបរវាងរបបផ្ដាច់ការ របបកុម្មុយនីស្ដ របបប្រជាធិតេយ្យ និង របបអនាធិបតេយ្យ ដូចតទៅៈ

| របប<br>ប្រភេទ | ផ្ដាច់ការ | កុម្មុយនីស្ដ | ប្រជាធិបតេយ្យ | អនាធិបតេយ្យ |
| --- | --- | --- | --- | --- |
| អំណាច | នៅលើអ្នកដឹកនាំ | នៅលើបក្ស | នៅលើប្រជាពលរដ្ឋ | នៅលើអ្នកខ្លាំង |
| ច្បាប់ | ចេញពីមាត់អ្នកដឹកនាំ | ចេញពីបក្ស | ចេញពីប្រជាពលរដ្ឋ ឬតាមរយៈតំណាង | គ្មានច្បាប់ |
| ផលប្រយោជន៍ | បានទៅអ្នកដឹកនាំ | បានទៅបក្ស | បានទៅប្រជាពលរដ្ឋ | បានទៅអ្នកខ្លាំង អ្នកមាន |



# សិទ្ធិមនុស្ស

## I. សេចក្តីផ្តើម

ក្រោយពីសង្គ្រាមលោកលើកទី ១ និង លើកទី ២ បានបំផ្លាញពិភពលោក និង សម្លាប់មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់ គេបានកត់សម្គាល់ឃើញថា អំពើឃោរឃៅ ការកាប់សម្លាប់ ការធ្វើទារុណកម្មគ្រប់បែបយ៉ាង និង អំពើគំរាមកំហែងពីសំណាក់អ្នកមានអំណាចអ្នកខ្លាំងទៅលើអ្នកទន់ខ្សោយគឺជាអំពើរំលោភសិទ្ធិមនុស្ស។ អំពើរំលោភសិទ្ធិមនុស្សនេះហើយដែលបណ្តាលឱ្យមានជម្លោះ។ ហើយជម្លោះតូចអាចបណ្តាលឱ្យមានជម្លោះធំរហូតដល់កើតមានសង្គ្រាមទៀតផង។

ហេតុនេះហើយ ទើបមហាសន្និបាតអង្គការសហប្រជាជាតិបានសម្រេចធ្វើការប្រកាសនូវសេចក្តីថ្លែងការណ៍សាកលស្តីអំពីសិទ្ធិមនុស្សនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៤៨។

**សេចក្តីថ្លែងការណ៍នោះមាន ៣០ មាត្រា ដែលមានខ្លឹមសារសង្ខេបដូចតទៅ:**

**មាត្រា ១:** មនុស្សរាល់រូបមានតម្លៃស្មើៗគ្នា

**មាត្រា ២:** ត្រូវចាត់ទុកមនុស្សគ្រប់រូបឱ្យបានស្មើៗគ្នា

**មាត្រា ៣:** សិទ្ធិមានជីវិតរស់នៅ

**មាត្រា ៤:** សិទ្ធិការពារមិនឱ្យគេយកទៅធ្វើជាខ្ញុំកញ្ជះ

**មាត្រា ៥:** សិទ្ធិមិនឱ្យមានទារុណកម្មមកលើខ្លួន

**មាត្រា ៦:** សិទ្ធិឱ្យគេទទួលស្គាល់ខ្លួនជាមនុស្ស

**មាត្រា ៧:** សិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់

**មាត្រា ៨:** សិទ្ធិសុំឱ្យច្បាប់ការពារខ្លួន

**មាត្រា ៩:** សិទ្ធិមានសេរីភាព

**មាត្រា ១០:** សិទ្ធិឱ្យមានការកាត់ក្តីត្រឹមត្រូវ

**មាត្រា ១១:** សិទ្ធិទទួលការកាត់ទោសសមស្របតាមច្បាប់

**មាត្រា ១២:** សិទ្ធិការពារជីវភាពឯកជនរបស់ខ្លួន

**មាត្រា ១៣:** សិទ្ធិធ្វើដំណើរទៅមកដោយសេរី

**មាត្រា ១៤:** សិទ្ធិទៅសុំការជ្រកកោននៅប្រទេសក្រៅ

**មាត្រា ១៥:** សិទ្ធិមានសញ្ជាតិមួយ

**មាត្រា ១៦:** សិទ្ធិរៀបចំគូស្រករ និង មានគ្រួសារ

**មាត្រា ១៧:** សិទ្ធិមានសម្បត្តិកម្មសិទ្ធិ

**មាត្រា ១៨:** សិទ្ធិមានជំនឿដោយសេរី

**មាត្រា ១៩:** សិទ្ធិនិយាយស្តី ឬសំដែងមតិដោយសេរី

**មាត្រា ២០:** សិទ្ធិរួមប្រជុំដោយសេរី

**មាត្រា ២១:** សិទ្ធិរួមចំណែកក្នុងសកម្មភាពនយោបាយ

**មាត្រា ២២:** សិទ្ធិមាននិរភ័យសង្គម

**មាត្រា ២៣:** សិទ្ធិមានការងារធ្វើ

**មាត្រា ២៤:** សិទ្ធិមានការសំរាក និង កំសាន្តកាយ

**មាត្រា ២៥:** សិទ្ធិមានជីវភាពរស់នៅសមរម្យ

**មាត្រា ២៦:** សិទ្ធិមានការអប់រំ

**មាត្រា ២៧:** សិទ្ធិទទួលផលក្នុងជីវភាពវប្បធម៌ និង រក្សាសិទ្ធិ

**មាត្រា ២៨:** សិទ្ធិឱ្យមានច្បាប់ការពារសិទ្ធិរបស់ខ្លួន

**មាត្រា ២៩:** កាតព្វកិច្ចចំពោះសហគមន៍ និង គោរពសិទ្ធិអ្នកដទៃ

**មាត្រា ៣០:** កាតព្វកិច្ចការពារខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ។

ជាមួយគ្នានេះដែរ សង្គ្រាមស៊ីវិល អំពើប្រល័យពូជសាសន៍ និង សង្គ្រាមឈ្លានពានក្នុងទសវត្សឆ្នាំ ៧០ និង ឆ្នាំ ៨០ នៅកម្ពុជាកន្លងទៅថ្មីៗនេះក៏បានបញ្ចប់ដោយសហគមន៍អន្តរជាតិតម្រូវអោយភាគីជម្លោះខ្មែរទាំងអស់រួមគ្នាចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ស្តីពីដំណោះស្រាយនយោបាយនៃជម្លោះនៅកម្ពុជានោះដោយសង្កត់ធ្ងន់លើបញ្ហាគោរពសិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ដូច្នេះតើសិទ្ធិមនុស្សជាអ្វី? សិទ្ធិមនុស្សមានសារៈសំខាន់យ៉ាងណាខ្លះ? សិទ្ធិអ្វីខ្លះដែលមនុស្សមាន ហើយយើងត្រូវអនុវត្តសិទ្ធិបែបណា?

## II. និយមន័យ

សិទ្ធិមនុស្សគឺជាសេចក្តីត្រូវការចាំបាច់របស់មនុស្សគ្រប់ៗរូបដែលមានតាំងពីកំណើតដើម្បីទាមទារនូវអ្វីៗដែលធ្វើឱ្យមនុស្សរស់នៅប្រកបដោយវិចារណញ្ញាណ និង សេចក្តីថ្លៃថ្នូរ។

## III. សារៈសំខាន់

មនុស្សខុសពីសត្វ ខុសពីរុក្ខជាតិ និង ខុសពីធម្មជាតិផ្សេងៗ ជាពិសេស មនុស្សត្រូវ មានមនសិការ មានវិចារណញ្ញាណ។ ដូច្នេះ ដើម្បីឱ្យមនុស្សរស់នៅប្រកប ដោយមនសិការ វិចារណញ្ញាណ និង សេចក្តីថ្លៃថ្នូរជាការចាំបាច់ដោយខានមិនបាន មនុស្សត្រូវតែមានសិទ្ធិ ហើយសិទ្ធិរបស់មនុស្សត្រូវតែបានគេគោរព។ មជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជាយល់ឃើញថា សិទ្ធិរបស់ប្រជាពលរដ្ឋជាប្រភពនៃអំណាចរបស់ប្រជាពល រដ្ឋ អំណាចរបស់ប្រជាពលរដ្ឋជាប្រភពនៃសុភមង្គលរបស់ប្រជាពលរដ្ឋ។ ដើម្បីឱ្យប្រជា ពលរដ្ឋទទួលបាននូវសុភមង្គលលុះត្រាតែប្រជាពលរដ្ឋមានសិទ្ធិ។ ដើមីឱ្យប្រជាពលរដ្ឋ ទទួលបាននូវសិទ្ធិទាំងនេះលុះត្រាតែ ប្រជាពលរដ្ឋបានយល់អំពីសិទ្ធិ ហ៊ានអនុវត្តសិទ្ធិ ហើយរដ្ឋាភិបាលត្រូវគោរពសិទ្ធិ។ សារៈសំខាន់នៃសិទ្ធិមនុស្ស មានជាអាទិ:

១. ដើម្បីការពារជីវិតរស់នៅរបស់មនុស្ស

២. ដើម្បីទាមទារនូវសេចក្តីត្រូវការចាំបាច់របស់មនុស្ស

៣. ដើម្បីសេរីភាពរបស់មនុស្សក្នុងសង្គម

៤. ដើម្បីសេចក្តីសុខសន្តិភាព និងសុវត្ថិភាព របស់មនុស្ស

៥. ដើម្បីសេចក្តីថ្លៃថ្នូររបស់មនុស្ស

៦. ដើម្បីការអភិវឌ្ឍន៏រីកចំរើនក្នុងជីវភាពរស់នៅរបស់មនុស្ស

៦. ដើម្បីរស់នៅស្មើភាពគ្នាចំពោះមុខច្បាប់ និង ចំពោះផលប្រយោជន៍នានាពីសង្គម។

## IV. សិទ្ធិផ្សេងៗ

យោងតាមស្មារតីនៃការប្រកាសសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨ របស់មហាសន្និបាតអង្គការសហប្រជាជាតិ គេសង្កេត

ឃើញសិទ្ធិសំខាន់ៗសំរាប់មនុស្សមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និង សិទ្ធិវប្បធម៌ ។

រហូតមកដល់ពេលនេះក្នុងការគោរពខ្លឹមសារនៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនៅកម្ពុជា យើងបានផ្តល់សច្ចាប័នទទួលស្គាល់លើកតិកាសញ្ញា និង អនុសញ្ញាអន្តរជាតិចំនួន ១១ :

១- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។

២- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសង្គម សេដ្ឋកិច្ច និង វប្បធម៌ ។

៣- អនុសញ្ញាស្តីពីការបង្ការ និង ផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

៤- អនុសញ្ញាអន្តរជាតិស្តីពីការបញ្ឈប់ និង ការផ្តន្ទាទោសឧក្រិដ្ឋកម្ម (ប្រកាន់ពណ៌សម្បុរ) អាប៉ាថេត ។

៥- អនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់ចោលសព្វបែបយ៉ាងនៃការប្រកាន់ពូជសាសន៍ ។

៦. អនុសញ្ញាប្រឆាំងទារុណកម្ម និង ការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ។

៧. អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ។

៨. អនុសញ្ញាស្តីពីសិទ្ធិកុមារ ។

៩. អនុសញ្ញាអន្តរជាតិទាក់ទងនឹងឋានៈនៃជនភៀសខ្លួន ។

១០. ពិធីសារទាក់ទងនឹងឋានៈនៃជនភៀសខ្លួន ។

១១. អនុសញ្ញាក្រុងហ្សឺណែវទាំងបួនស្តីអំពីការប្រព្រឹត្តិរបស់ទាហាន និង ស្តីពីច្បាប់មនុស្សធម៌ក្នុងគ្រាមានសង្គ្រាម ។

## V. សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

### ១. សិទ្ធិពលរដ្ឋ

ក. *សិទ្ធិរស់រានមានជីវិត* : មនុស្សគ្រប់រូបត្រូវតែបានទទួលការការពារជីវិត និង មិនត្រូវឱ្យគេសម្លាប់ឡើយ។ ដើម្បីបំពេញលក្ខ័ណ្ឌនេះ រដ្ឋត្រូវធានាចរាចរអោយមានសណ្តាប់ធ្នាប់ មានសន្តិសុខ បញ្ចៀសសង្គ្រាម រំដោះមីន ឱសថមានគុណ ភាពចំណីអាហារមិនហួសពេលវេលាកំណត់ និង គ្មានជាតិពុល ស្ពាន ថ្នល់មាំទាំ.....។

ខ. *សិទ្ធិទទួលបាននូវសេចក្តីថ្លៃថ្នូរ* : កើតមកដំបូង មនុស្សបរិសុទ្ធដូចគ្នា មានតម្លៃស្មើគ្នា។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបាននូវសេចក្តីថ្លៃថ្នូរដូចគ្នាដោយគ្មានជនណាយកទៅធ្វើជាខ្ញុំកញ្ជះ ធ្វើទារុណកម្ម និយាយបរិហារបង្ខូចកេរ្តិ៍ឈ្មោះ.....។

គ. *សេរីភាពខាងជំនឿ និង មនសិការផ្ទាល់ខ្លួន* : មនុស្សគ្រប់រូបអាចសំរេចចិត្តដោយសេរីតាមសម្បជញ្ញៈផ្ទាល់ខ្លួន។ គេអាចជឿ ជ្រើសរើស ប្តូរសាសនា ឬបង្រៀនសាសនាដល់អ្នកដទៃ។

ឃ. *ឯកជនភាព ស្វ័យភាពផ្ទាល់ខ្លួន* : គ្មានអ្នកណាបង្ខិតបង្ខំឱ្យគេផ្លាស់ប្តូររបៀបរស់នៅឡើយ បើគ្មានការយល់ព្រមពីសាមុីខ្លួន។ មនុស្សគ្រប់រូបមានសិទ្ធិទៅរកច្បាប់ឱ្យជួយការពារ បើមានការរំលោភ ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងអ្នកដទៃ។ ការចូលផ្ទះគេដោយគ្មានមូលហេតុ និង មិនប្រាប់មុនគឺជាការរំលោភ។

ង. *សេរីភាពក្នុងការបញ្ចេញមតិ និង ចូលរួមក្នុងសមាគម* : មនុស្សគ្រប់រូបមានសេរីភាពក្នុងការគិតគូរសំដែងមតិ និង និយាយស្តី។ គ្មានអ្នកណាឃាត់ឃាំងមិនអោយ

និយាយស្ដីបញ្ចេញយោបល់យកពតិមាន ឬផ្ដល់ពតិមានតាមរយៈសៀវភៅ កាសែត វិទ្យុ ទូរទស្សន៍ ឬមធ្យោបាយផ្សេងៗទៀតឡើយ ។សេរីភាពទាំងនេះភាគច្រើនត្រូវទទួលការបង្ក្រាប គាបសង្កត់ពីរដ្ឋអំណាច អាជ្ញាធរ។ ឧទាហរណ៍ៈ រដ្ឋអំណាច អាជ្ញាធរយកលេសវិទ្ធង្សនាដើម្បីរក្សាសន្តិសុខដែលធ្វើឱ្យមនុស្សចង្អៀតចង្អល់ ។

ច. ***សិទ្ធិក្នុងការធ្វើដំណើរដោយសេរី*** : មនុស្សគ្រប់រូបមានសេរីភាពធ្វើដំណើរឆ្ងាយជិតទូទាំងប្រទេស។ ក្នុងកាលៈទេសៈប្រទេសជាតិមានភាពអាសន្ន ជម្ងឺឆ្លង ជម្ងឺអាសន្នរោគជាដើម រដ្ឋអាចចេញបំរាមគោចរ ប៉ុន្តែបើចូលទៅប្រទេសដទៃត្រូវមានការអនុញ្ញាតពីប្រទេសនោះ ។

ឆ. ***សិទ្ធិរួចចាកផុតពីអំណាចផ្ដាច់ការរបស់រដ្ឋាភិបាល*** : ក្នុងប្រទេសកាន់របបប្រជាធិបតេយ្យពិតប្រាកដ រដ្ឋាភិបាលដែលជាអ្នកអនុវត្តកម្មវិធីនយោបាយជាតិ ត្រូវគោរពអនុវត្តយ៉ាងម៉ឺងម៉ាត់គ្រប់ប្រការជំពូកនៃរដ្ឋធម្មនុញ្ញ។ រដ្ឋាភិបាលត្រូវដោះស្រាយគ្រប់សំណើ សំណូមពររបស់ប្រជាពលរដ្ឋ។ រដ្ឋាភិបាលត្រូវការពារប្រជាពលរដ្ឋឱ្យអនុវត្តសិទ្ធិរបស់គេ។ ឧទាហរណ៍ៈ ការសំដែងមតិ ជាបាតុកម្ម កូដកម្ម ការតវ៉ាទាមទារអ្វីមួយដោយសន្តិវិធី រដ្ឋាភិបាលត្រូវមានភារកិច្ចការពារ តែមិនមែនប្រើមធ្យោបាយបង្ក្រាបឡើយ ។

ជ. ***សិទ្ធិទទួលបាននូវការការពារពីច្បាប់*** : ច្បាប់សំរាប់ការពារឱ្យមនុស្សទូទៅ។ អ្នកបំពានច្បាប់ រំលោភលើសិទ្ធិ ប៉ះពាល់ទ្រព្យសម្បត្តិកិត្តិយសរបស់យើង យើងត្រូវប្ដឹងទៅតុលាការរកយុត្តិធម៌ទារជម្ងឺចិត្ត។

ការនិយមបក្សពួកជាការរំលោភច្បាប់។ អ្នកបំពានច្បាប់ត្រូវមានទោស រដ្ឋអំណាចរំលោភពលរដ្ឋ ត្រូវសងជម្ងឺចិត្តអ្នករងគ្រោះ តុលាការកាត់ទោសដាក់ទណ្ឌកម្មផ្ទុយពីច្បាប់ត្រូវទទួលកំហុស និង សងជម្ងឺចិត្ត.....។

ឈ. ***សិទ្ធិទទួលនូវសេរីភាព និង សន្តិសុខផ្ទាល់ខ្លួន*** : មនុស្សគ្រប់រូបមិនត្រូវបានគេចាប់ចងដោយរំលោភ ឬឃុំឃាំង។ ជនដែលត្រូវគេចាប់ខ្លួនមានសិទ្ធិទាមទារភ្លាមៗឱ្យគេបង្ហាញដីកាចាប់ខ្លួន និង ប្រាប់ហេតុផល និង ប្រភេទនៃបទ ល្មើស។ ការចាប់ចងខុសច្បាប់ត្រូវប្តឹងទាមទារជម្ងឺចិត្ត។

## ២. សិទ្ធិនយោបាយ

ក. ***សិទ្ធិសេរីភាពក្នុងការនិយាយស្តី សារពត៌មាន ការប្រជុំ ការតវ៉ា:*** ពលរដ្ឋគ្រប់រូបមានសេរីភាពពេញទីក្នុងការគិតគូរ សំដែងមតិ និង និយាយស្តី។ ការឃាត់ឃាំងមិនឱ្យបញ្ចេញមតិ និយាយស្តី យកពតិមាន ឬផ្តល់ពតិមានតាមរយៈសៀវភៅ កាសែត វិទ្យុ ទូរទស្សន៍ ឬតាមមធ្យោបាយផ្សេងៗ គឺជាការរំលោភ សិទ្ធិការប្រជុំរៀបចំធ្វើបាតុកម្មដោយសន្តិវិធីគឺជាសិទ្ធិពេញទីរបស់ពលរដ្ឋ។

**"ការហាមប្រជុំ ហាមធ្វើបាតុកម្មអហិង្សា គឺរំលោភសិទ្ធិ ការប្រើកម្លាំងអាវុធទៅបំបាត់បាតុករដែលគ្មានអាវុធ ដែលជាភស្តុស្លូតត្រង់ សិស្ស ឬនិស្សិត ជាការរំលោភដ៏គួរឱ្យខ្ពើមរអើម"**

ការអនុវត្តន៍សិទ្ធិសេរីភាពនេះត្រូវជៀសវាងការប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។

***ខ. សិទ្ធិបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោត*** : ក្នុងប្រទេសកាន់របបប្រជាធិបតេយ្យ ការបោះឆ្នោតមានសារៈសំខាន់ជាអាយុជីវិតជាតិក្នុងការជ្រើសរើសផ្លាស់ប្តូរអ្នកដឹកនាំ (មធ្យោបាយគ្មានការបង្ហូរឈាម)។ ពលរដ្ឋខ្មែរគ្រប់អាយុបោះឆ្នោតត្រូវប្រើសិទ្ធិឱ្យអស់លទ្ធភាព ដើម្បីសំដែងឆន្ទៈតាមមនសិការផ្ទាល់ខ្លួន។

***គ. សិទ្ធិចូលរួមបោះឆ្នោតដោយសេរី យុត្តិធម៌ និង ទៀងទាត់*** : សិទ្ធិនេះត្រូវប្រជាពលរដ្ឋយកមកអនុវត្តតាមមនសិការឆន្ទៈផ្ទាល់ខ្លួន គ្មានការបង្ខិតបង្ខំគំរាមកំហែង គ្មានការទិញដូរ។ អាជ្ញាធររៀបចំការបោះឆ្នោតត្រូវតែឯករាជ្យ អព្យាក្រឹតឥតល្អៀង និងរៀបចំការបោះឆ្នោតតាមប្រតិទិនពេលវេលាទៀងទាត់ពេលចប់អាណត្តិនីមួយៗ។ ការបោះឆ្នោតដែលស្របតាមលទ្ធិប្រជាធិបតេយ្យត្រូវគោរពគោលការណ៍សំខាន់ៗ ៩ ចំណុចដូចខាងក្រោម :

- គណៈកម្មាធិការ និង មន្ត្រីរៀបចំការបោះឆ្នោតត្រូវតែឯករាជ្យ អព្យាក្រឹត និងទទួលបាននូវការបណ្តុះបណ្តាលយ៉ាងល្អដើម្បីបំពេញភារកិច្ចរបស់ខ្លួន។
- កិច្ចសង្កេតការណ៍ជាតិ និង អន្តរជាតិត្រូវមាននៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតហើយអង្គការក្រៅរដ្ឋាភិបាលអាចចូលរួមជាអ្នកបណ្តុះបណ្តាល អ្នកសង្កេតការណ៍ ផងដែរ។
-ការបង្កើតឡើងនូវបរិយាកាសនយោបាយមួយប្រកបដោយសន្តិភាព សុវត្ថិភាព សេរីភាព និង យុត្តិធម៌សំរាប់គ្រប់គណបក្សនយោបាយ បេក្ខជន និង អ្នកបោះឆ្នោត។
- រដ្ឋាភិបាល គណបក្សនយោបាយ និង បេក្ខជនទាំងអស់ត្រូវតែគោរពសិទ្ធិមនុស្សយ៉ាងពេញលេញ។

- ការផ្តល់សិទ្ធិស្មើគ្នាចំពោះគ្រប់គណបក្សនយោបាយ និង បេក្ខជនទាំងអស់ក្នុងការប្រើប្រាស់ប្រព័ន្ធពត៌មាន។ រីឯស្ថាប័ន និង សម្ភារៈរបស់រដ្ឋមិនត្រូវយកទៅប្រើប្រាស់ជាផលប្រយោជន៍របស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ។

- ការចុះឈ្មោះគណបក្សនយោបាយ និង បេក្ខជនត្រូវធ្វើដោយសេរី ហើយការចុះឈ្មោះអ្នកបោះឆ្នោតត្រូវប្រព្រឹត្តទៅដោយគ្មានលំអៀង ស្របតាមនីតិវិធី និង ច្បាប់។

- ដំណើរនៃយុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ និង បេក្ខជនត្រូវធ្វើឡើងដោយសេរី ដោយមានការគោរពសេរីភាពក្នុងការចូលរួមប្រជុំ និង គាំទ្រការបញ្ចេញមតិ និង ការប្រាស្រ័យទាក់ទងជាមួយអ្នកបោះឆ្នោត ។

- ការបោះឆ្នោតប្រព្រឹត្តទៅតាមការជ្រើសរើសដោយសេរី ដោយសម្ងាត់ ដោយគ្មានការបំភិតបំភ័យ ឬធ្វើទុក្ខបុកម្នេញ និង គ្មានវត្តមានកម្លាំងសន្តិសុខក្នុងបរិវេណនៃការិយាល័យបោះឆ្នោត។

- ហឹបឆ្នោត ការរាប់សន្លឹកឆ្នោត និង លទ្ធផលនៃការបោះឆ្នោតត្រូវឱ្យមានការជឿទុកចិត្ត និង មានការទទួលស្គាល់ ។

### ឃ. *សិទ្ធិបង្កើតសមាគម ឬគណបក្សនយោបាយ (សិទ្ធិធ្វើយុទ្ធនាការសម្រាប់គណបក្សនយោបាយ និង សិទ្ធិចូលរួមក្នុងគណបក្ស នយោបាយ)*

សិទ្ធិនេះត្រូវបានចែងយ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញមាត្រា ៤២។ រដ្ឋាភិបាលត្រូវបង្កលក្ខណៈងាយស្រួលដល់សមាគម គណបក្សនយោបាយក្នុងការធ្វើសកម្មភាពស្របច្បាប់របស់ពួកគេ។ ឧទាហរណ៍ៈ រដ្ឋបាលគ្រប់ជាន់ថ្នាក់ត្រូវប្រកាន់ជំហរអព្យាក្រឹត(បរិយាកាសនយោបាយ) បើកសិទ្ធិសេរីភាពស្របតាមច្បាប់ដល់គ្រប់បក្សនយោបាយ ក្នុងការធ្វើយុទ្ធនាការ ការរួមប្រជុំ។ ជនណា ឬអាជ្ញាធរណាបំបិទសិទ្ធិសេរីភាពនេះមានន័យថា ប្រឆាំងនឹងរដ្ឋធម្មនុញ្ញ។

ង. <u>*សិទ្ធិមានលទ្ធភាពស្មើគ្នាក្នុងការចូលរួមបំរើការងារសាធារណៈ(រួមទាំងសិទ្ធិទទួលការជ្រើសរើសឱ្យកាន់តំណែងការងារ)៖*</u> ពលរដ្ឋគ្រប់រូបមានសិទ្ធិធ្វើការងារ ដើម្បីជីវភាពរស់នៅ។ ការជ្រើសរើសមុខរបរ គឺជាសមត្ថភាព ជាជំនាញរបស់បុគ្គលម្នាក់ៗ។ រដ្ឋត្រូវធានាប្រាក់កម្រៃគ្រប់គ្រាន់ និង សមរម្យ។ ជាការចាំបាច់ពលរដ្ឋមានសិទ្ធិសុំប្រាក់ឧបត្ថម្ភពេលគ្មានការងារធ្វើ។ ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ គេអាចបង្កើតសហជីព និង ចូលជាសមាជិកសហជីព។ ប្រទេសណាដែលមានប្រជាពលរដ្ឋភាគច្រើនឥតការងារធ្វើ សេដ្ឋកិច្ចប្រទេសនេះមិនរីកចំរើនឡើយ។

ច. <u>*សិទ្ធិស្មើគ្នារវាងបុរស និង ស្ត្រីក្នុងសកម្មភាពនយោបាយ៖*</u> រដ្ឋធម្មនុញ្ញមាត្រា ៣៥ ចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាព នយោបាយ និង មានសិទ្ធិចូលរួមក្នុងកិច្ចការរបស់ប្រទេសជាតិក្នុងសកម្មភាពផ្សេងៗរបស់រដ្ឋាភិបាល ដូចជាធ្វើជាអ្នករាជការ ទាហាន ឬនគរបាល ឬអាចឈរឈ្មោះជាតំណាងរាស្ត្រ។ ឧទាហរណ៍៖ ស្ត្រីជាអ្នកដឹកនាំនៅប្រទេសអង់គ្លេស បង់ក្លាដេស ប៉ាគីស្ថាន ហ្វីលីពីន ឥណ្ឌូនេស៊ី ....។

## VI. ការអនុវត្តន៍សិទ្ធិ

បើគ្រាន់តែស្គាល់ និង យល់ពីសិទ្ធិនោះហើយនៅស្ងៀមមិនទាន់គ្រប់គ្រាន់ទេ។ ពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យត្រូវចេះអនុវត្តសិទ្ធិឱ្យមានប្រសិទ្ធភាព។ *ពលរដ្ឋជាម្ចាស់ឆ្នោតបានប្រគល់សេចក្តីទុកចិត្តអោយអ្នកតំណាងរបស់ខ្លួនទៅគ្រប់គ្រងស្ថាប័នសំខាន់ៗ ដែល* មាន ព្រឹទ្ធសភា រដ្ឋសភា រដ្ឋាភិបាល....ដើម្បីទៅធានា និង ការពារ សិទ្ធិគ្រប់បែបយ៉ាង។ ក្នុងករណីតំណាងទាំងនេះមិនយកចិត្តទុកដាក់យើងត្រូវ៖

- ធ្វើសំណូមពរ

- ធ្វើការតវ៉ាតាមរយៈកូដកម្ម ឬបាតុកម្មអហិង្សា
- តស៊ូមតិ
- ដាក់ពាក្យបណ្ដឹង

*** * តើត្រូវប្ដឹងទៅណាខ្លះ?**

- ប្ដឹងទៅអាជ្ញាធរដែលជារដ្ឋអំណាចភូមិ ឃុំ ស្រុក ខេត្តរបស់លោកអ្នក។
- ប្ដឹងទៅតុលាការ សាលាដំបូង សាលាឧទ្ធរណ៍ និង តុលាការកំពូល។
- ធ្វើរបាយការណ៍ ឬប្ដឹងដល់អង្គការសិទ្ធិមនុស្សក្នុងស្រុក និង អង្គការសិទ្ធិមនុស្សអន្តរជាតិប្រចាំតំបន់របស់លោកអ្នកដូចជា :
  - មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង ក្រុមគោលដៅប្រចាំសហគមន៍
  - អង្គការអាដហុក
  - អង្គការលីកាដូ
  - អង្គការគំពារការពារក្ដីកម្ពុជា
  - អង្គការជំនួយផ្នែកច្បាប់កម្ពុជា
  - អង្គការសិទ្ធិមនុស្សសហប្រជាជាតិជាដើម
- លោកអ្នកអាចរាយការណ៍ ដាក់ពាក្យបណ្ដឹងអំពីករណីរំលោភសិទ្ធិតាមរយៈតំណាងរាស្ត្ររបស់លោកអ្នក។
- ប្រសិនបើលោកអ្នកមានការភ័យខ្លាច មិនហ៊ានធ្វើការរាយការណ៍ ឬក៏ប្ដឹង លោកអ្នកអាចពឹងពាក់មិត្តភក្ដិដែលជិតស្និទ្ធ ឬក៏ញាតិសន្ដានបងប្អូនរបស់លោកអ្នកឱ្យជួយធ្វើរបាយការណ៍ ឬក៏ប្ដឹងអំពីករណីរំលោភទៅអង្គការសិទ្ធិមនុស្សប្រចាំតំបន់របស់លោកអ្នក។

*** * កត្តាដែលសំខាន់បំផុត លោកអ្នកត្រូវធ្វើជាចាំបាច់គឺៈ**

❶ រាយការណ៍ ឬក៏ប្តឹងឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

❷ សរសេរ ឬក៏ព្យាយាមចងចាំរឿងហេតុដែលកើតឡើងឱ្យបានក្បោះក្បាយរួមមានបទវិលោភ ជនល្មើស ទីកន្លែង ពេលវេលា កាលបរិច្ឆេទ អង្គហេតុ ។

❸ សូមលោកអ្នកចងចាំថា លោកអ្នកមានសិទ្ធិស្នើសុំឱ្យអង្គការដែលលោកអ្នកបានប្តឹងនោះ រក្សាការសម្ងាត់ និង មិនបញ្ចេញឈ្មោះ ។

**** លោកអ្នកអាចរកមេធាវីជួយការពារក្តីបណ្តឹងរបស់លោកអ្នក ។**

*** *ក្នុងករណីដែលលោកអ្នកបានអនុវត្តនូវចំណុចណែនាំខាងលើនេះហើយ តែមិនបានលទ្ធផល លោកអ្នកអនុវត្តនូវសិទ្ធិចុងក្រោយ គឺឈប់បោះឆ្នោតឱ្យជននោះ ក្រុមនោះ ឬគណបក្សនោះទៀត ។*

**"ការគោរពសិទ្ធិមនុស្ស គឺជួយពង្រឹងលទ្ធិប្រជាធិបតេយ្យឱ្យកាន់តែមានភាពល្អបរិសុទ្ធ"**

**" សិទ្ធិមនុស្សដែលចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា "**

## រដ្ឋធម្មនុញ្ញ ជំពូកទី ៣
## អំពីសិទ្ធិ និង ករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១:** ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និង កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និង ករណីកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២:** ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិតមានសេរីភាព និង មានសន្តិសុខផ្ទាល់ខ្លួន ។ ទោសប្រហារជីវិតមិនឱ្យមានឡើយ ។

**មាត្រា ៣៣:** ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។ ប្រជាពលរដ្ឋដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤:** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និង អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំមានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានយ៉ាងតិច៤០ ឆ្នាំអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។ បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត។

**មាត្រា ៣៥:** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ។ សេចក្ដីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និង ដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។

**មាត្រា ៣៦:** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្ដីត្រូវការរបស់សង្គម។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារនៅក្រៅផ្ទះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និង អត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និង ចូលជាសមាជិកសហជីពនេះ។ ការរៀបចំ និង ការប្រព្រឹត្តិទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់។

**មាត្រា ៣៧:** សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិវិធីត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់។

**មាត្រា ៣៨:** ច្បាប់រ៉ាប់រងមិនមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និង សេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធធានាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដៃដល់អ្នករួមប្រព្រឹត្ត និង អ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តីមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។ ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩:** ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និង សំណង់ជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០:** សេរីភាពក្នុងការដើរឆ្ងាយជិត និង តាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅនៅប្រទេសក្រៅឬវិលត្រលប់មកវិញបាន ។ ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅដ្ឋាន និង អាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិតតាមសារទូរលេខ ទូរពុម្ព ទូរគមនាគមន៍ និង តាមទូរស័ព្ទត្រូវបានធានា ។ ការឆែកឆេរលំនៅដ្ឋានសម្ភារៈ វត្ថុ និង លើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១:** ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ

មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិបានឡើយ ។

របបសារពត៌មានត្រូវបានរៀបចំដោយច្បាប់ ។

**មាត្រា ៤២:** ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និង គណបក្ស នយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញ ទៅមក ការពារសមិទ្ធិផលជាតិ និង សន្តាប់ធ្នាប់សង្គម។

**មាត្រា ៤៣:** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានាក្នុងលក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿសាសនាដទៃទៀតដល់សណ្តាប់ធ្នាប់ និង សន្តិសុខ សាធារណៈ។

ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។

**មាត្រា ៤៤:** ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់។ ការដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌។

**មាត្រា ៤៥:** ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់។ បុរស និង ស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និង គ្រួសារ។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និង តាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធ មួយ។

**មាត្រា ៤៦:** អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និង អំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់។ ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារដោយមូលហេតុមានគភ៌។

នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយទទួលប្រាក់បៀវត្ស និង ដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និង អត្ថប្រយោជន៍សង្គមផ្សេងៗទៀត។ រដ្ឋ និង

សង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារីជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺឱ្យកូនទៅរៀន និង មានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧:** មាតាបិតាមានកាតព្វកិច្ចចិញ្ចឹម ថែរក្សា និង អប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។ កូនមានករណីកិច្ចចិញ្ចឹម និង បីបាច់ថែរក្សាមាតាបិតាជរាតាមទំនៀមទំនាប់ខ្មែរ ។

**មាត្រា ៤៨:** រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និង ការរៀនសូត្ររបស់កុមារ ឬនាំឱ្យអន្តរាយដល់កុមារ ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩:** ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និង គោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និង ការពារមាតុភូមិ ។ កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០:** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍ អធិបតេយ្យជាតិ និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និង កម្មសិទ្ធិស្របច្បាប់របស់ឯកជន ។

# ពលរដ្ឋវិជ្ជា

## I. សេចក្តីផ្តើម

នៅក្នុងប្រទេសនីមួយៗដែលប្រកាន់នូវលទ្ធិប្រជាធិបតេយ្យសេរីពិតប្រាកដ ប្រជាពលរដ្ឋម្នាក់ៗត្រូវតែបានដឹងថា តើខ្លួនមានជាតិជាអ្វី? រស់នៅលើទឹកដីរបស់នរណា? ហើយនៅទីកន្លែងនោះមានប្រព័ន្ធគ្រប់គ្រងអំណាចបែបណា? ចំណេះដឹងជាមូលដ្ឋានខាងលើនេះ អាចញ៉ាំងឱ្យពលរដ្ឋគ្រប់រូបមានទំនាក់ទំនងស្រួលក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ ចំណេះដឹងផ្នែកនេះគឺមានឈ្មោះថា ពលរដ្ឋវិជ្ជាដែលជាផ្នែកមួយនៃផ្នែកទាំងបីដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លើកយកមកបង្រៀនដល់ប្រជាពលរដ្ឋក្នុងដំណើរឆ្ពោះទៅកាន់ប្រជាធិបតេយ្យសេរីរបស់ខ្លួន។

## II. និយមន័យ

ពលរដ្ឋវិជ្ជា = ពល + រដ្ឋ + វិជ្ជា

- ពល មានន័យថា កម្លាំង
- រដ្ឋ មានន័យថា ប្រទេស
- វិជ្ជា មានន័យថា ចំណេះដឹង

ដូច្នេះពលរដ្ឋវិជ្ជាគឺជាចំណេះដឹងរបស់កម្លាំងរដ្ឋដើម្បី យកទៅអនុវត្តក្នុងការរស់នៅប្រចាំថ្ងៃរបស់ខ្លួន។

## ១. ពលរដ្ឋ

ពលរដ្ឋជាកំលាំងរបស់រដ្ឋរួមមាន អ្នកដឹកនាំ និង ពលរដ្ឋសាមញ្ញ។

* **អ្នកដឹកនាំ:** គឺជាអ្នកគ្រប់គ្រងរដ្ឋដោយទទួលអំណាចពីប្រជាពលរដ្ឋនៃប្រទេសនោះ។ ក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋផ្ទេរអំណាចអោយអ្នកដឹកនាំតាមរយៈការបោះឆ្នោត។ អ្នកដឹកនាំទាំងអស់នោះ គឺជាអ្នកបំរើប្រជាពលរដ្ឋព្រោះអ្នកទាំងនោះទទួលប្រាក់បៀវត្សពីរដ្ឋតាមរយៈការបង់ពន្ធ ឬធនធានផ្សេងៗរបស់រដ្ឋក៏ដូចជារបស់ប្រជាពលរដ្ឋដែរ។ ក្នុងការបំពេញភារកិច្ចផ្សេងៗ អ្នកដឹកនាំត្រូវតំកល់ ប្រយោជន៍របស់ប្រជាពលរដ្ឋខ្ពស់ជាងគេបំផុត និង ត្រូវគោរពច្បាប់ព្រមទាំងកិច្ចសន្យាទាំងឡាយដែលលោកបានធ្វើការសន្យាជាមួយប្រជាពលរដ្ឋក្នុងពេលយុទ្ធនាការឃោសនា។ លើសពីនេះទៅទៀត អ្នកដឹកនាំត្រូវមានលក្ខណសម្បត្តិល្អ សមត្ថភាព ខ្ពស់ សីលធម៌ថ្លៃថ្នូរ.. ...។ល។

* **ពលរដ្ឋសាមញ្ញ:** ចំពោះពលរដ្ឋធម្មតាដែលជាម្ចាស់អំណាច ម្ចាស់ប្រទេសត្រូវមានភារកិច្ច កាតព្វកិច្ច និង សីលធម៌ផងដែរដូចជា:

- ត្រូវគោរពច្បាប់ បង់ពន្ធដារផ្សេងៗ ជួយការពារជាតិ ចូលរួមការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ

- ត្រូវចូលរួមធ្វើសេចក្តីសំរេចនានាក្នុងការអភិវឌ្ឍន៍ភូមិ ឃុំ-សង្កាត់ ស្រុក-ខណ្ឌ ខេត្ត-ក្រុង........

- ត្រូវរក្សាការពារវប្បធម៌ អរិយធម៌ទំនៀមទំលាប់ល្អរបស់ខ្លួនដូចជា ភាសា អក្សរ របាំ តូរ្យតន្ត្រី ក្បាច់ចំលាក់ ប្រាសាទ ជាដើមដែលបញ្ជាក់អំពីអត្ត សញ្ញាណជាតិរបស់ខ្លួនដូចជាទង់ជាតិ ភ្លេងជាតិ ចំរៀងជាតិ សញ្ញាជាតិ.....។ល។

## ២. រដ្ឋ ឬប្រទេស

រដ្ឋ គឺជាការប្រមូលផ្តុំមនុស្សដែលរស់នៅលើដែនលំហកំណត់ច្បាស់លាស់ក្រោមរបបនយោបាយមួយដូចគ្នា។ ដូច្នេះ ដើម្បីឱ្យបានក្លាយទៅជារដ្ឋ ឬប្រទេសត្រូវមានលក្ខណៈ ៤ យ៉ាងគឺ:

- ទឹកដី
- ពលរដ្ឋ
- ប្រព័ន្ធរដ្ឋាភិបាល ឬអំណាចនយោបាយ និង
- ការទទួលស្គាល់អន្តរជាតិ

ប្រទេសយើងសព្វថ្ងៃមានឈ្មោះថា ប្រទេសកម្ពុជា ឬព្រះរាជាណាចក្រកម្ពុជា មានផ្ទៃក្រឡា (ដីគោក កោះ វាលទំនាបភ្នំ) ទំហំ ១៨១.០៣៥ គីឡូម៉ែត្រការ៉េ និង មានលំហដែនសមុទ្រទំហំ ៩៥.000 គីឡូម៉ែត្រការ៉េ និង ដែនអាកាសគ្របដណ្តប់លើផ្ទៃក្រឡាទាំងអស់នេះ។

## ៣. អត្តសញ្ញាណជាតិ

អត្តសញ្ញាណជាតិខ្មែរ គឺការសំគាល់នៃជាតិខ្មែរមាន:

- ទង់ជាតិខ្មែរដែលមានបីពណ៌ ហើយមានរូបអង្គរវត្ត
- សញ្ញាជាតិខ្មែរ គឺព្រះសង្វារដែលមានឆពណ្ណរង្សី មានរូបស្វេតច្ឆ័ត្រ រាជសីហ៍ ព្រះខ័ននៅក្រោមមកុដរាជ្យ និង ពាក្យព្រះចៅក្រុងកម្ពុជា។

- សាសនាដែលខ្មែរប្រតិបត្តិ គឺព្រះពុទ្ធសាសនា។ ពុទ្ធសាសនាគឺជាគ្រឹះនៃសង្គមខ្មែរផ្តល់នូវសីលធម៌ ហើយសីលធម៌ គឺជាមូលដ្ឋាននៃការគោរព សិទ្ធិមនុស្ស និង គោរពច្បាប់។

## III. ការគ្រប់គ្រងរដ្ឋ

នៅក្នុងប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ អំណាចគ្រប់គ្រងប្រទេសជាអំណាចរបស់ប្រជាពលរដ្ឋគ្រប់រូប។ ប៉ុន្តែដោយហេតុថាប្រជាពលរដ្ឋមានច្រើនហើយមាននិន្នាការសង្គមផ្សេងៗគ្នានោះ ទើបការគ្រប់គ្រងដោយពលរដ្ឋផ្ទាល់មិនអាចប្រព្រឹត្តទៅបាន។ ដើម្បីអោយការគ្រប់គ្រងរដ្ឋនេះទទួលបាននូវលទ្ធផលល្អ ប្រជាពលរដ្ឋដែលជាម្ចាស់អំណាចបានប្រគល់ភារកិច្ចនេះជូនទៅយន្តការផ្សេងៗអោយគ្រប់គ្រងជំនួស។ យន្តការនេះហើយដែលគេនិយមអោយឈ្មោះថាស្ថាប័នជាតិ។ ស្ថាប័នគ្រប់គ្រងនេះមានភាពខុសប្លែកគ្នាពីរដ្ឋមួយទៅរដ្ឋមួយដោយសាររបបនយោបាយនៃរដ្ឋនោះ។

ក្នុងពិភពលោកយើងនេះ គេគ្រប់គ្រងប្រទេសទៅតាមរបបនយោបាយផ្សេងៗគ្នាដូចជា

### ១. របបប្រជាធិបតេយ្យសេរី

ជារបបគ្រប់គ្រងមួយដែលផ្តល់ជូនប្រជាពលរដ្ឋនូវសិទ្ធិសេរីភាពយ៉ាងបរិបូរណ៍ក្នុងការជ្រើសរើសអ្នកដឹកនាំតាមការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង យុត្តិធម៌ និងទៀងទាត់ និង ទៅតាមការនិយមនៃប្រទេសនីមួយៗដូចជា

- **តាមបែបសភានិយម:** របបគ្រប់គ្រងនេះ ប្រជាពលរដ្ឋត្រូវបោះឆ្នោតជ្រើសរើសរដ្ឋសភារួចហើយទើបរដ្ឋសភានោះបោះឆ្នោតតែងតាំងនាយករដ្ឋមន្ត្រីដើម្បីដឹកនាំរដ្ឋាភិបាល ហើយរដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរដ្ឋសភា និង

ប្រជាពលរដ្ឋ។ ចំពោះប្រទេសដែលមានព្រះមហាក្សត្រគ្រងរាជ្យគេអាចហៅថា របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។

ឧទាហរណ៍: ប្រទេសថៃ អង់គ្លេស ព្រះរាជាណាចក្រកម្ពុជា ............។

**- តាមបែបប្រធានាធិបតីនិយម :** របបនេះ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសប្រធានាធិបតី និង បោះឆ្នោតជ្រើសរើសសភាដោយផ្ទាល់ ហើយប្រធានាធិបតីជ្រើសតាំង និង ដឹកនាំរដ្ឋាភិបាល។

ឧទាហរណ៍: សហរដ្ឋអាមេរិក ឥណ្ឌូនេស៊ី ហ្វីលីពីន.............។

**- តាមបែបចំរុះ :** របបនេះ ស្ថាប័ននីតិប្រតិបត្តិដឹកនាំដោយប្រធានាធិបតី និងនាយករដ្ឋមន្ត្រី។ ប្រធានាធិបតីត្រូវបានប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសដោយផ្ទាល់ ឯនាយករដ្ឋមន្ត្រីត្រូវជ្រើសរើសដោយសភា។ ប្រធានាធិបតីមានអំណាចខ្លាំងជាងនាយករដ្ឋមន្ត្រី។

ឧទាហរណ៍: ប្រទេសបារាំង ហ្វាំងឡង់ ប៉ូឡូញ ប៊ុលហ្គារី.........។

## ២. របបផ្តាច់ការ

របបនេះ ប្រជាពលរដ្ឋពុំមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសអ្នកដឹកនាំទេ ហើយអំណាចទាំងអស់ត្រូវស្ថិតនៅក្នុងកណ្តាប់ដៃបុគ្គលតែម្នាក់ ឬមនុស្សមួយក្រុម ឬគណបក្សមួយ។ របបផ្តាច់ការមានដូចជា របបកុម្មុយនីស្ត របបសង្គមនិយម របបយោធានិយម ឬរបបរាជាធិបតេយ្យ។

ឧទាហរណ៍: ប្រទេសកូរ៉េខាងជើង ភូមា គុយបា ចិន យួន ប៊្រុយណេ.........។

## IV. ស្ថាប័នជាតិធំៗ

ការគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យសេរី ប្រជាពលរដ្ឋដែលជាម្ចាស់អំណាច បានប្រគល់សិទ្ធិអំណាចរបស់ខ្លួនជូនស្ថាប័នជាតិអោយដឹកនាំ និង គ្រប់គ្រងប្រទេសជំនួស តាមរយៈការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និង ទៀងទាត់ ។ ស្ថាប័នជាតិធំៗនោះមាន:

### ១. ស្ថាប័ននីតិបញ្ញត្តិ (រដ្ឋសភា និង ព្រឹទ្ធសភា)

#### ក. រដ្ឋសភា

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ (បង្កើតច្បាប់)។ សមាជិករដ្ឋសភាមានតំណាងរាស្ត្រយ៉ាងតិច ១២០ រូប។ មកដល់ឆ្នាំ ២០០៣ នេះតំណាងរាស្ត្រមានចំនួន ១២៣ រូប ដែលជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និង តាមវិធីជ្រើសរើសឆ្នោតជាសំងាត់ ។

- ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលអនុវត្តនូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ជារបបសភានិយមក្នុងនោះ ប្រជាពលរដ្ឋជាអ្នកបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលជាសមាជិករដ្ឋសភាដោយផ្ទាល់ ហើយជាអ្នកទទួលអំណាចផ្ទាល់ ពីប្រជាពលរដ្ឋ។

- ក្នុងរបបប្រជាធិបតេយ្យសេរីពហុបក្ស តំណាងរាស្ត្រមានតួនាទីយ៉ាងតិច ៣ គឺ:

១. ពិភាក្សា និង អនុម័តច្បាប់

២. តាមដានរដ្ឋាភិបាលក្នុងការអនុវត្តន៏ច្បាប់

៣. ស្វែងយល់អំពីសំណូមពរ និង កង្វល់របស់ប្រជាពលរដ្ឋដើម្បីស្នើដល់រដ្ឋាភិបាលដោះស្រាយ ។

- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ។ នីតិកាលរបស់រដ្ឋសភាមានតំណត់ ៥ ឆ្នាំ។

- តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋនៅក្នុងមណ្ឌលរបស់ខ្លួនទេ។ តាមការស្នើសុំពីសមាជិកមួយភាគដប់ (១/១០) យ៉ាងតិចរដ្ឋសភាអាចអញ្ជើញឥស្សរជននៅក្នុងជួររដ្ឋាភិបាលមកបំភ្លឺពីបញ្ហា សំខាន់ណាមួយ។

- សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង នាយករដ្ឋមន្ត្រីជាអ្នកផ្តួចផ្តើមធ្វើច្បាប់។ រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រីពីតំណែង ដោយអនុម័តញត្តិបន្ទោសតាមសំលេងឆ្នោត ២/៣ នៃសមាជិករដ្ឋសភា។

## ខ. ព្រឹទ្ធសភា

- ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ។
- ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និង រដ្ឋាភិបាល។
- ព្រឹទ្ធសភាជាអ្នកជួយពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ដាក់ជូនដោយរដ្ឋសភាមុននឹងត្រូវយកទៅប្រកាសឱ្យប្រើ។
- ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។
- សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និង ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។
- ពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោតមានអាយុយ៉ាងតិច ៤០ ឆ្នាំមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា។

សមាជិករដ្ឋសភា និង សមាជិកព្រឹទ្ធសភាជាតំណាងប្រជាពលរដ្ឋទូទាំងប្រទេសមិនមែនគ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលខ្លួនតែប៉ុណ្ណោះទេ។

## ២. ស្ថាប័ននីតិប្រតិបត្តិ (រដ្ឋាភិបាល)

រដ្ឋាភិបាលជាអង្គការនីតិប្រតិបត្តិ ពោលគឺជាអ្នកអនុវត្តច្បាប់គ្រប់គ្រងប្រទេស ចាត់ចែងកិច្ចការគ្រប់គ្រងរដ្ឋក្នុងក្របខណ្ឌច្បាប់ និង ឈរលើមូលដ្ឋានច្បាប់ព្រមទាំងអំណាចដែលរដ្ឋសភាផ្តល់ឱ្យដូចជារក្សាសណ្តាប់ធ្នាប់ក្នុងប្រទេស ការពារជាតិទំនាក់ទំនងការទូត រក្សាសុខុមាលភាពប្រជាពលរដ្ឋ (អប់រំ សុខាភិបាល សេដ្ឋកិច្ច សង្គមកិច្ច) ។ល។

- គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រី
- សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដឹកនាំក្រសួងនានា និង ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភាអំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។
- សមាជិកគ្រប់រូបនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រី និង ចំពោះរដ្ឋសភា អំពីសកម្មភាពអនុវត្តការងាររបស់ខ្លួន។
- សមាសភាពរាជរដ្ឋាភិបាលមាននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ។

នៅក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋានមានមន្ត្រីបំរើការងារចែកជា ២ ក្រុមគឺក្រុមមន្ត្រីក្របខ័ណ្ឌនយោបាយ និង ក្រុមមន្ត្រីក្របខ័ណ្ឌរដ្ឋបាល។

### ក. មន្ត្រីក្របខ័ណ្ឌនយោបាយ

មន្ត្រីក្នុងក្របខ័ណ្ឌនេះមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ។ មន្ត្រីទាំងនេះមានភារកិច្ចកំណត់ និង អនុវត្តគោលនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ មន្ត្រីទាំងនេះជាអ្នកធានាការអនុវត្តន៍ច្បាប់ និង ដឹកនាំការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការណា

ដែលជាសមត្ថកិច្ចរបស់ស្ថាប័ននីតិបញ្ញត្តិ និង ស្ថាប័នតុលាការ។ មន្ត្រីទាំងនោះទទួលប្រាក់បំណាច់ពីរដ្ឋ ហើយមានអាណត្តិច្បាស់លាស់។

ដោយឡែកនៅព្រះរាជាណាចក្រកម្ពុជា មុខងារអនុរដ្ឋលេខាធិការពុំមែនស្ថិតនៅក្នុងក្របខ័ណ្ឌនយោបាយ ឬក្របខ័ណ្ឌរដ្ឋបាលទេ ប៉ុន្តែមុខងារនេះមានអាណត្តិដូចគ្នានឹងរដ្ឋាភិបាលដែរ។

## ខ. មន្ត្រីក្របខ័ណ្ឌរដ្ឋបាល

ចំណែកមន្ត្រីក្នុងក្របខ័ណ្ឌរដ្ឋបាលវិញ មានឋានៈចាប់ពីអគ្គនាយកចុះមកដល់បុគ្គលិកធម្មតាដែលបំរើការងារតាមក្រសួង មន្ទីរ ខេត្ត-ក្រុង នានាទូទាំងប្រទេស។

ក្របខ័ណ្ឌរដ្ឋបាល គឺជាអ្នកទទួលអនុវត្តនូវបញ្ជាពីក្របខ័ណ្ឌនយោបាយ ពោលគឺរាជរដ្ឋាភិបាលដើម្បីប្រយោជន៍ទូទៅ ឬផលប្រយោជន៍សាធារណៈ។ ប៉ុន្តែមិនមែនសំរាប់ផលប្រយោជន៍របស់គណបក្សណាមួយឡើយ និង ត្រូវប្រកាន់ជំហរអព្យាក្រឹត។

មន្ត្រីក្របខ័ណ្ឌរដ្ឋបាល ធ្វើការជាប់ជាប្រចាំថ្ងៃ ទោះបីថ្ងៃបុណ្យ ឬថ្ងៃសំរាកក៏ដោយ ក៏ត្រូវមានអ្នកប្រចាំការជាប់ជានិច្ចដែរ។

**ឧទាហរណ៍:** នគរបាល កងរាជអាវុធហត្ថជាតិ មន្ទីរពេទ្យ ស្ថាប័នបំរើសេវាទឹក និង ភ្លើង ឬផ្នែកដឹកជញ្ជូនជាដើម។

**ចំពោះអាជ្ញាធរដែនដី** (ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់) ត្រូវអនុវត្តនូវសេចក្តីសំរេចទាំងឡាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដែនដី រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ ........ជូនប្រជាពលរដ្ឋ។

គួរកត់សំគាល់ថា នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃ ០៣ វិច្ឆិកា ឆ្នាំ ២០០២ មក យើងបានធ្វើវិមជ្ឈការនៅថ្នាក់ឃុំ-សង្កាត់ ពោលគឺក្រុមប្រឹក្សាឃុំ-សង្កាត់នីមួយៗ មានលទ្ធភាពបំពេញតួនាទី ការងារតាមមូលដ្ឋានរៀងៗខ្លួនដោយមិនចាំបាច់ទទួលបញ្ជា ពីថ្នាក់លើទៀតឡើយ ។ ល្គឹកណាមានការដោះស្រាយខ្លួនឯង មិនចេញទើបស្នើយោបល់ ទៅថ្នាក់លើតាមលំដាប់ថ្នាក់ (តែមិនមែនសុំបញ្ជាទេ) ដែលយើងហៅថាប្រពន្ធ័ វិសហមជ្ឈការ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវជ្រើសតាំងតាមរយៈការបោះឆ្នោតនៅក្នុង ឃុំ-សង្កាត់របស់ខ្លួន។ ភូមិគឺ ជាអង្គភាពមួយចំណុះអោយ ឃុំ-សង្កាត់ ហើយប្រធានភូមិ នីមួយៗត្រូវធ្វើការជ្រើសរើសតាមការណែនាំរបស់ក្រសួងមហាផ្ទៃ (តាមច្បាប់ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់) ។

សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់មិនមែនជាមន្ត្រីក្នុងក្របខ័ណ្ឌរដ្ឋបាលទេព្រោះក្រុម ប្រឹក្សាឃុំ-សង្កាត់កើតឡើងពីការបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាពលរដ្ឋមិនមែន តែងតាំងដោយរដ្ឋាភិបាលឡើយ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ទទួលប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល មែន តែគ្មានប្រាក់ចូលនិវត្ត ឬឋានន្តរស័ក្តិក្នុងក្របខ័ណ្ឌរដ្ឋបាលឡើយ ។

## ៣. ស្ថាប័នតុលាការ ឬអំណាចតុលាការ

### ក. តុលាការ

ស្ថាប័នតុលាការ ជាស្ថាប័នឯករាជ្យ មិនចំណុះអោយស្ថាប័ននីតិបញ្ញត្តិ ឬនីតិ ប្រតិបត្តិឡើយ ។ ស្ថាប័ននេះត្រូវបង្កើតឡើងដើម្បីវិនិច្ឆ័យនូវរាល់អំពើបំពានច្បាប់ ឬអំពើ បង្កអន្តរាយដល់សង្គមជាតិ ។ តុលាការគ្រប់ដណ្តប់លើរឿងក្តីទាំងអស់ ។ នៅព្រះរាជាណា ចក្រកម្ពុជាមានប្រព័ន្ធតុលាការពីរគឺ :

- **តុលាការជាន់ទាប:** តុលាការខេត្ត-ក្រុង និង តុលាការយោធា។ តុលាការ ខេត្ត-ក្រុងតាំងនៅទីរួមខេត្ត-ក្រុង រីឯតុលាការយោធាតាំងនៅរាជធានី ភ្នំពេញ។
- **តុលាការជាន់ខ្ពស់:** សាលាឧទ្ធរណ៍ និង តុលាការកំពូល។ តុលាការនេះតាំងនៅទីក្រុងភ្នំពេញ។

នៅអមតុលាការជាន់ទាបមានមន្ទីរអយ្យការ ហើយនៅអមតុលាការជាន់ខ្ពស់មានមហាអយ្យការ។ មន្ត្រីតុលាការជាន់ទាបមានប្រធាន អនុប្រធានតុលាការ ចៅក្រម និង ក្រឡាបញ្ជី។ ចំណែកឯនៅអយ្យការមានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង និង ក្រឡាបញ្ជី។ នៅតុលាការជាន់ខ្ពស់មានប្រធាន អនុប្រធានតុលាការ ចៅក្រម និង ក្រឡាបញ្ជី។ រីឯមហាអយ្យការមាន អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា និង ក្រឡាបញ្ជី។

ក្នុងករណីមានបណ្តឹងព្រហ្មទណ្ឌ ឬបណ្តឹងអាជ្ញាគេត្រូវធ្វើពាក្យបណ្តឹងទៅអយ្យការ (ព្រះរាជអាជ្ញា) ហើយត្រូវប្តឹងទៅប្រធានតុលាការ កាលណាមានបណ្តឹងរដ្ឋប្បវេណី។

ព្រះរាជអាជ្ញាជាដើមបណ្តឹងអាជ្ញា និង ជាអ្នកធ្វើការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយជាគូក្តីរណបក្នុងរឿងក្តីរដ្ឋប្បវេណី ដោយបំពេញភារកិច្ចជាអ្នកផ្តល់យោបល់ផ្នែកច្បាប់។

## ខ. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតនៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ ព្រះមហាក្សត្រអាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសំរេចដាក់វិន័យលើចៅក្រម ព្រះរាជអាជ្ញាដែលបានប្រព្រឹត្តខុសតាមរយៈក្រុមប្រឹក្សាវិន័យ។ ការដាក់វិន័យនេះ ឧត្តមក្រុមប្រឹក្សានៃ អង្គចៅក្រមរួមប្រជុំក្រោមអធិបតីនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអម តុលាការកំពូលអាស្រ័យទៅលើការដាក់វិន័យនោះទាក់ទងទៅនឹងចៅក្រម ឬព្រះរាជអាជ្ញា។ ឯកសារដែលពាក់ព័ន្ធនឹងការដាក់វិន័យត្រូវបញ្ជូនទៅលេខាធិការដ្ឋាននៃឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រមយ៉ាងយូរបំផុតរយៈពេល ១៥ ថ្ងៃ មុនការបើប្រជុំក្រុមប្រឹក្សាវិន័យ។

## V. អំណាចផ្សេងៗ

### ១. ព្រះមហាក្សត្រ

- គ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ
- ជាប្រមុខរដ្ឋមួយជាជីវិត
- មិនអាចទរណារំលោភបំពានបានឡើយ
- ជានិមិត្តរូប នៃឯកភាពជាតិ និង និរន្តរភាពជាតិ
- ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ
- ជាអ្នកធានាឯករាជជាតិ អធិបតេយ្យ និង បូរណភាពទឹកដី
- ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ ការគោរពសិទ្ធិ និង សិទ្ធិសញ្ញាអន្តរជាតិនានា
- ជាអាជ្ញាកណ្តាលដើម្បីធានាការប្រព្រឹត្តិទៅនៃអំណាចសាធារណៈឱ្យទៀងទាត់
- ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ
- មានព្រះរាជសិទ្ធិក្នុងការបន្ធូរបន្ថយ និង លើកលែងទោស
- ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតនៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ

- របបរាជានិយម ជារបបជ្រើសតាំង ( ដោយក្រុមប្រឹក្សារាជសម្បត្តិ) ។

## ២. ក្រុមប្រឹក្សាធម្មនុញ្ញ

- មានសិទ្ធិពិនិត្យ និង សំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ព្រឹទ្ធសភា ។

- មានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ។

- ទទួលបណ្តឹងស្តីពីធម្មនុញ្ញភាពនៃច្បាប់តាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ។

- ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួន ១/៤ តំណាងរាស្ត្រចំនួន ១/១០ ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។

- សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

## ៣. សមាជជាតិ

- សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់អំពីកិច្ចការផ្សេងៗដែលជាប្រយោជន៍ជាតិ និង លើកបញ្ហា សំណូមពរ និង មតិជូនរដ្ឋអំណាចដោះស្រាយ ។

- ពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

- សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំនៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។

- សមាជជាតិប្រព្រឹត្តទៅក្រោមអធិបតីភាពនៃព្រះមហាក្សត្រ ហើយអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និង ជូនរដ្ឋាភិបាលពិចារណា។

## ៤. ប្រព័ន្ធផ្សព្វផ្សាយ

ប្រព័ន្ធផ្សព្វផ្សាយមានវិទ្យុ ទូរទស្សន៍ កាសែត ឬសារពត៌មាន ព្រឹត្តិប័ត្រ ទស្សនាវដ្ដី ទូរស័ព្ទ ឬទូរសារជាដើម។ ក្នុងរបបប្រជាធិបតេយ្យ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានចាត់ទុកជាអំណាចទី ៤ ដែលជាអ្នកតាមដានត្រួតពិនិត្យមើលការអនុវត្តន៍របស់ស្ថាប័ននានាហើយផ្សព្វផ្សាយពីសកម្មភាពនៃស្ថាប័ននោះដល់ប្រជាពលរដ្ឋ និង មានសារៈសំខាន់ណាស់សំរាប់ផ្ដល់ពត៌មានពីប្រជាពលរដ្ឋទៅអ្នកដឹកនាំ និង ពីអ្នកដឹកនាំទៅប្រជាពលរដ្ឋវិញ។

## ៥. សង្គមស៊ីវិល

សង្គមស៊ីវិលមាន អង្គការ សមាគម សហជីព តំណាងវិជ្ជាជីវៈ ប្រព័ន្ធសារពត៌មាន...។ល។ ក្នុងសង្គមប្រជាធិបតេយ្យ សង្គមស៊ីវិលគឺជាដៃគូដ៏សំខាន់របស់រដ្ឋាភិបាល ព្រោះសង្គមស៊ីវិលជាអ្នកធ្វើការផ្ទាល់ជាមួយគ្រប់ស្រទាប់ប្រជាពលរដ្ឋហើយសង្គមស៊ីវិល ជាអ្នកជួយបំពេញនូវកិច្ចការខ្លះៗដែលរដ្ឋាភិបាលមិនបានបំពេញសព្វគ្រប់ព្រមទាំងផ្ដល់មតិផ្សេងៗដល់អ្នកដឹកនាំ។

## ៦. គណបក្សនយោបាយ

គឺជាការប្រមូលផ្ដុំរបស់មនុស្សមួយក្រុម ដែលមានទស្សនៈ និង គោលការណ៍គ្រប់គ្រងដឹកនាំរដ្ឋដូចគ្នា ឬប្រហាក់ប្រហែលគ្នាទៅតាមកម្មវិធី ឬបន្ទាត់នយោបាយដែលក្រុមពលរដ្ឋក្នុងគណបក្សនោះសំរេចថានឹងយកទៅអនុវត្តនៅពេលដែលគណបក្សខ្លួនឈ្នះឆ្នោតកាន់រដ្ឋាភិបាល។

## VI. សេចក្តីសន្និដ្ឋាន

ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ត្រូវតែបានសិក្សានូវពលរដ្ឋវិជ្ជានេះគ្រប់គ្នាព្រោះជាមធ្យោបាយតែមួយនាំឱ្យប្រជាពលរដ្ឋទាំងនោះយល់កាន់តែច្បាស់នូវសិទ្ធិ និង ករណីកិច្ចរបស់ខ្លួនយល់ពីប្រជាធិបតេយ្យ ហើយអាចអនុវត្ត និង ធ្វើសេចក្តីសំរេចចិត្តបានត្រឹមត្រូវក្នុងការជ្រើសរើសអ្នកដឹកនាំបានល្អនាសម័យបោះឆ្នោតម្តងៗ ក៏ដូចជាការជួយសំរួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់គាត់ដែរ ។

**" ប្រជាពលរដ្ឋ ជាចៅហ្វាយ មន្ត្រីរដ្ឋាភិបាលជាអ្នកបំរើរបស់ប្រជាពលរដ្ឋ "**

## បំព្រួញបង្ហាញផ្លូវដោះស្រាយបញ្ហាតាមរយៈសភា




*រៀបរៀងដោយបណ្ឌិត ឈឹម ផលវរុណ*

## បំព្រួញបង្ហាញអំពីដំណើរការវិវត្តន៍នៃគំនិតផ្តួចផ្តើមប្រជាពលរដ្ឋ

**ជំហានទី ១**

ពលរដ្ឋម្នាក់ ចាប់អារម្មណ៍ថា
បែបបទសព្វថ្ងៃពុំត្រឹមត្រូវ ឬ
ចង់ទប់ស្កាត់ ភាពអសកម្ម
ហើយចង់ កែលំអជំរុញ
អភិវឌ្ឍន៍ ។

**ជំហានទី ២**

តវ៉ាជាបុគ្គលទៅអាជ្ញាធរ
ក្រុមប្រឹក្សាឃុំ-សង្កាត់
គណបក្សកែមិនបានសំរេច

**ជំហានទី ៣**

បង្កើតក្រុមផ្តួចផ្តើម ដើម្បី
ចូលរួមខ្នះខ្នែង ជំរុញការងារ
អភិវឌ្ឍន៍មូលដ្ឋាន ។

**ជំហានទី ៤**

ចូលរួមសកម្មក្នុងកិច្ចការ
អភិវឌ្ឍន៍ និងកែទំរង់

**ជំហានទី ៥**

គណបក្សចាប់ផ្តើមយកចិត្តទុកដាក់
ធ្វើការបកស្រាយតាមប្រព័ន្ធពត៌មាន
ធ្វើការចោទសួរទៅរដ្ឋបាល-អាជ្ញាធរ

**ជំហានទី ៦**

រដ្ឋបាល-អាជ្ញាធរ និងក្រុម
អ្នកដឹកនាំពិចារណា និងរក
លទ្ធភាពសំរបសំរួល

**ជំហានទី ៧**

ដំណោះស្រាយសមស្រប
ត្រូវបានយកមកពិនិត្យ
ក្រុមប្រជាពលរដ្ឋ ឯក
ភាព ឬក៏ត្រូវទាមទារ
កែលំអទៀត ។

*រៀបរៀងដោយ បណ្ឌិត ឈឹម ផលវរុណ*

# គំរូពាក្យបណ្តឹង

## គំរូទី ១: អំពើបទល្មើសឧក្រិដ្ឋរំលោភសេពសន្ថវៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................អាយុ.........ឆ្នាំ............ជាតិ...........មុខរបរ...........ទីលំនៅភូមិ..........................ឃុំ.................ស្រុក......................ខេត្ត...............។

**សូមគោរពជូន**

**លោកមេភូមិ.....................**

ក្បិតខ្ញុំបាទកើតទុក្ខមិនសុខចិត្តនឹងទាហានមិនស្គាល់ឈ្មោះនៅអង្គភាពទ័ពព្រៃក្នុងឃុំរបស់យើង ដែលបានចាប់ប្រពន្ធរបស់ខ្ញុំយកទៅរំលោភសេពសន្ថវៈនៅព្រៃខាងក្រោយផ្ទះរបស់ខ្ញុំបាទចំងាយ ១០០ ម៉ែត្រពីផ្ទះកាលពីយប់មិញ គឺយប់ថ្ងៃទី...........ខែ............ឆ្នាំ.........ម៉ោង...........ដោយដំបូងពួកវាទាំងពីរនាក់បានចូលមកសុំជ្រកភ្លៀងនៅផ្ទះរបស់ខ្ញុំបាទ ហើយបានសុំថ្នាំជក់មួយបារីម្នាក់។

ពេលរាំងភ្លៀង ពួកគេក៏លាខ្ញុំបាទចេញទៅបន្តិចក្រោយមក ក៏ត្រឡប់មកវិញចាប់ខ្ញុំបាទចងដោយភ្ជង់ប្រពន្ធខ្ញុំឱ្យទៅជាមួយពួកគេ ហើយក៏រំលោភសេពសន្ថវៈ ប្រពន្ធរបស់ខ្ញុំបាទ

នៅក្រោយផ្ទះតែម្តង។ ពីរម៉ោងក្រោយមក ទើបប្រពន្ធរបស់ខ្ញុំបាទត្រឡប់មកផ្ទះវិញ និយាយរឿងនេះប្រាប់បាទ។

សូមលោកមេភូមិមេត្តាជួយធ្វើអន្តរាគមន៍ ស្វែងរកយុត្តិធម៌ឱ្យខ្ញុំបាទផង។

.............ថ្ងៃទី.........ខែ............ឆ្នាំ.............

**ហត្ថលេខា ឬស្នាមមេដៃអ្នកប្តឹង**

**ឈ្មោះ**.........................

## គំរូទី២: អំពីបទល្មើសឧក្រិដ្ឋរំលោភសេពសន្ថវៈមួយទៀត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ពាក្យបណ្តឹង</u>**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................អាយុ........ឆ្នាំ............ជាតិ..........មុខរបរ.......

....ទីលំនៅភូមិ........................ឃុំ................ស្រុក.....................

ខេត្ត...............។

**សូមគោរពជូន**

**ព្រះរាជអាជ្ញាអមតុលាការ..................**

**<u>កម្មវត្ថុ</u> :** សុំប្តឹងពីឈ្មោះ.....................................ភេទ.......អាយុប្រហែល.....

(១) និង ម្នាក់ទៀតមិនស្គាល់ឈ្មោះ...................................អាយុប្រហែល......

(២) ជាទ័ពឈរជើងនៅ...................................ពីបទ "**រំលោភសេពសន្ថវៈ**"។

តាមកម្មវត្ថុខាងលើនេះ សូមលោកព្រះរាជអាជ្ញា មេត្តាជ្រាបនូវដំណើររឿងដូចតទៅ :

កាលពីថ្ងៃទី........ខែ............ឆ្នាំ.........ចៅស្រីរបស់នាងខ្ញុំឈ្មោះ............. អាយុ.......ឆ្នាំ និង ប្អូនជីដូនមួយរបស់វាឈ្មោះ............................ភេទ.......អាយុ ..........ឆ្នាំ បានចេញទៅឃ្វាលគោជាមួយក្មេងក្នុងភូមិជាច្រើនទៀតនៅខាងកើតភូមិ។ ពេលនោះ ចៅស្រីរបស់នាងខ្ញុំ និង ប្អូនជីដូនមួយរបស់វាបានចូលទៅរកកាច់ពោតនៅក្នុង

ចំការ ស្រាប់តែលេចមុខទាហានខាងលើចេញមកម្នាក់ចាប់ចៅស្រីរបស់នាង ខ្ញុំខ្ទប់មាត់ទាញចូលទៅក្នុងព្រៃ។ ម្នាក់ទៀតនៅភ្ជង់បួនជីដូនមួយរបស់វាមិនឱ្យស្រែកម្នាក់ដែលចាប់ចៅស្រីរបស់នាងខ្ញុំយកទៅក្នុងព្រៃបាន រំលោភសេពសន្ថវៈចៅស្រីនាងខ្ញុំរួចហើយក៏ស្រែកហៅគ្នាគេដែលកំពង់ភ្ជង់បួនជីដូនមួយវាឱ្យរំលោភម្តង ទើបស្គាល់តែឈ្មោះជនល្មើសម្នាក់តែប៉ុណ្ណោះ។

ដូចនេះ សូមព្រះរាជអាជ្ញាអមតុលាការ មេត្តាចាត់ការជនល្មើសទាំងពីរយកមកផ្តន្ទាទោសតាមច្បាប់ និង សុំឱ្យជនល្មើសទាំងពីរបង់ប្រាក់ជំងឺចិត្តចំនួន ..........................រៀលដោយអនុគ្រោះ។

................ថ្ងៃទី..........ខែ..................ឆ្នាំ........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង**

**ឈ្មោះ**......................................

គំរូទី៣: អំពីបទល្មើសឧក្រិដ្ឋមនុស្សឃាតគិតទុកជាមុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ....................អាយុ.......ឆ្នាំ ជាតិ.............មុខរបរ..............
ទីលំនៅភូមិ.....................ឃុំ....................ស្រុក...................ខេត្ត.............។

**សូមគោរពជូន**

**ព្រះរាជអាជ្ញារងតុលាការ**.........................

**កម្មវត្ថុ:** សុំប្តឹងពីឈ្មោះ.......................ភេទ........អាយុ.......ឆ្នាំ សញ្ជាតិ..............
មុខរបរ...............ទីលំនៅភូមិ.................ឃុំ.....................ស្រុក.....................ខេត្ត. .................ប៉ាន:...................................ពីបទ " **សម្លាប់មនុស្ស** "។

តាមកម្មវត្ថុខាងលើនេះ ខ្ញុំសូមជំរាបជូនព្រះរាជអាជ្ញាជ្រាបដូចតទៅ :

កាលពីថ្ងៃទី........ខែ.........ឆ្នាំ..........វេលាម៉ោង ៥ ព្រឹកខ្ញុំបាទបានភ្ញាក់ពីដំណេកចុះពីលើផ្ទះមកដី ដើរទៅបន្ទោរបង់នៅព្រៃខាងក្រោយផ្ទះស្រាប់តែជនខាងលើក្នុងឯកសណ្ឋានជាទាហាន បានចេញពីគុម្ពោតព្រៃក្បែរខ្លួនរបស់ខ្ញុំបាទ មកភ្ជង់ខ្ញុំបាទដោយគំរាមថា បើហ៊ានស្រែកអញបាញ់សម្លាប់ចោល។ ពេលនោះម្នាក់នៅភ្ជង់ខ្ញុំ បាទឯម្នាក់ទៀតដើរឡើងទៅលើផ្ទះរបស់ខ្ញុំបាទ។ រំពេចនោះមានការផ្ទុះអាវុធពីរគ្រាប់ នៅលើផ្ទះរួចហើយជនទាំងពីរនោះក៏នាំគ្នាគេចខ្លួនទៅទិសខាងកើតចូលទៅក្នុងព្រៃបាត់ទៅ

ដោយពួកគេពុំធ្វើអ្វីដល់រូបខ្ញុំបាទទេ។ ភ្លាមនោះ ខ្ញុំបាទក៏រត់ឡើងមកលើផ្ទះស្រាប់តែឃើញកូនប្រុសរបស់ខ្ញុំបាទឈ្មោះ............................... បានដេកស្លាប់នៅលើផ្ទះត្រូវគ្រាប់កាំភ្លើងពីរគ្រាប់ត្រង់ក្បាល។

ជនទាំងពីរនាក់ដូចមានឈ្មោះខាងលើ ខ្ញុំបាទមិនដែលស្គាល់ទេ ប៉ុន្តែសាក្សីឈ្មោះ.........................ជាអ្នកប្រាប់ព្រោះគេធ្លាប់ស្គាល់ជនទាំងពីរ និង បានឃើញសកម្មភាពរបស់ជនទាំងពីរនាក់នៅពេលកើតហេតុ។

ហេតុដូច្នេះ សូមលោកព្រះរាជអាជ្ញា មេត្តានាំខ្លួនជនល្មើសទាំងពីរនាក់យកមកផ្តន្ទាទោសតាមច្បាប់ និង បង្ខំឱ្យសងប្រាក់ជំងឺចិត្តចំនួន......................រៀលមកខ្ញុំបាទដោយអនុគ្រោះ។

សូមលោកព្រះរាជអាជ្ញា ទទួលនូវសេចក្តីគោរពយ៉ាងជ្រាលជ្រៅអំពីខ្ញុំ។

..............ថ្ងៃទី......ខែ........ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃដើមបណ្តឹង**

**ឈ្មោះ**.................................

គំរូទី៤: អំពីបទល្មើសឧក្រិដ្ឋមនុស្សឃាតគិតទុកជាមុន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹង

ខ្ញុំបាទឈ្មោះ.....................អាយុ.........ឆ្នាំ ជាតិ............មុខរបរ............
ទីលំនៅភូមិ.................ឃុំ..............ស្រុក................ខេត្ត................។

**សូមគោរពជូន**

លោកប្រធានសមាគមសិទ្ធិមនុស្ស...................

**កម្មវត្ថុ:** សុំប្ដឹងពីឈ្មោះ....................ភេទ.........អាយុ.......ឆ្នាំ សញ្ជាតិ............ មុខរបរធ្វើអាជីវកម្មព្រៃឈើ ពីបទ " **ប៉ុនប៉ងសម្លាប់រូបខ្ញុំ** "។

ត្បិតក្រោយពីកាសែត................លេខ.........ចេញផ្សាយថ្ងៃទី.........ខែ..... .. ..............ឆ្នាំ........រួមមកមានសាក្សីកាសែត...................និង ឈ្មោះ.................. បានប្រាប់ខ្ញុំបាទថាឈ្មោះខាងលើមានបំណងចង់សម្លាប់រូបខ្ញុំ ដោយសារតែខ្ញុំបាទសរសេរអត្ថបទកាសែតមួយច្បាប់ក្រោមចំណងជើងថា "............" ដែលមានការប៉ះពាល់ដល់សកម្មភាពប្រកបអាជីវកម្មព្រៃឈើខុសច្បាប់របស់ពួកគេ។ បញ្ហានេះខ្ញុំ បាទមានការព្រួយបារម្ភណាស់ ព្រោះជនខាងលើកំពុងស្វែងរកខ្ញុំដើម្បីសម្លាប់ចោល។

ហេតុនេះ សូមលោកប្រធានសមាគមមេត្តាជួយធ្វើអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីមានវិធានការទប់ស្កាត់អំពើប៉ុនប៉ងរបស់ជនល្មើសដោយអនុគ្រោះ ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពយ៉ាងជ្រាលជ្រៅអំពីខ្ញុំបាទ ។

ភ្នំពេញ ថ្ងៃទី.........ខែ....................ឆ្នាំ.........

**មេត្តលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង**

**ឈ្មោះ**.......................

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

■ **មជ្ឈមណ្ឌលសិទ្ធមនុស្សកម្ពុជា តំបន់៤ ខេត្តកំពង់ចាម**

- អាស័យដ្ឋាន ផ្ទះលេខ ៤១ ក្រុម ២ ផ្លូវ ៧ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។
- ទូរស័ព្ទ និង ទូរសារៈ (៨៥៥-៤២) ៩៤១ ៩៤៣.
- ទូរស័ព្ទដៃៈ ០១១ ៨៨៨ ៤៧៧

■ **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តំបន់ ៥ ខេត្តក្រចេះ**

- អាស័យដ្ឋាន ផ្ទះលេខ ៧៤៧ ផ្លូវលេខ ៦ ភូមិវត្ត ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ។
- ទូរស័ព្ទ និងទូរសារៈ (៨៥៥-៧២) ៩៧១ ៧០៥.
- ទូរស័ព្ទដៃៈ ០១១ ៦១៨ ៦៥០

■ **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តំបន់ ៦ ខេត្តបាត់ដំបង**

- អាស័យដ្ឋានផ្ទះលេខ ៣៨៦ ភូមិអញ្ចាញ ឃុំអូរចារ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។
- ទូរស័ព្ទ និងទូរសារៈ (៨៥៥-៥៣) ៩៥៣ ២១៨. ទូរស័ព្ទដៃៈ ០១២ ៩៩៨ ០៦៧

■ **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តំបន់៧ ខេត្តសៀមរាប**

- អាស័យដ្ឋាន ផ្ទះលេខ ០២៧៧ ក្រុម ៧ ភូមិចុងកៅស៊ូ ឃុំស្លក្រោម ស្រុកសៀមរាប ខេត្តសៀមរាប ។
- ទូរស័ព្ទ និង ទូរសារៈ (៨៥៥-៦៣) ៩៦៣ ០៤៣.
- ទូរស័ព្ទដៃៈ ០១១ ៦២៧ ៨៩១

# បញ្ជីការ "ការបណ្តុះបណ្តាលដើម្បីសហគមន៍ប្រជាធិបតេយ្យ"

យើងរួមគ្នាធ្វើដំណើរចេញពី ខ្មៅ ខ្លាច ឃ្លាន ឆ្ពោះទៅកាន់ ចេះ ហ៊ាន មាន

ប្រជាពលរដ្ឋម្នាក់ៗ :

- ☐ ១. ត្រូវដឹងថាខ្លួនជាម្ចាស់អំណាច និង ជាម្ចាស់វាសនានៃប្រទេសជាតិខ្លួន។
- ☐ ២. ត្រូវដឹងថា រដ្ឋាភិបាល មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ និង អាជ្ញាធរគ្រប់ជាន់ថ្នាក់ ជាអ្នកបំរើ និង ការពារប្រជាពលរដ្ឋដោយគ្មានរើសអើង។
- ☐ ៣. ត្រូវដឹងថាមនុស្សម្នាក់ៗសុទ្ធតែមានតម្លៃ សេចក្តីថ្លៃថ្នូរ និង ស្មើភាពគ្នាចំពោះមុខច្បាប់។
- ☐ ៤. ត្រូវដឹងថាខ្លួនមានសិទ្ធិទទួលព័ត៌មានដោយសេរី។
- ☐ ៥. ត្រូវហ៊ានអនុវត្តសិទ្ធិចូលរួមប្រជុំ និង សំដែងមតិតាមឆន្ទៈខ្លួន។
- ☐ ៦. ត្រូវហ៊ានរួបរួមគ្នាការពារកម្មសិទ្ធិឯកជន និង កម្មសិទ្ធិសាធារណៈ។
- ☐ ៧. ត្រូវហ៊ានរួបរួមគ្នាទប់ស្កាត់នូវអំណាចផ្តាច់ការ អំពើហិង្សា និង អំពើពុករលួយក្នុងសង្គម។
- ☐ ៨. ត្រូវហ៊ានប្រឆាំងនឹងនិរទណ្ឌភាព និង ភាពអយុត្តិធម៌ផ្សេងៗក្នុងសង្គម។
- ☐ ៩. ត្រូវទទួលបានការពិនិត្យ និង ដោះស្រាយយ៉ាងម៉ត់ចត់ពីអង្គការរដ្ឋនូវរាល់សេចក្តីស្នើសុំទាំងឡាយរបស់ខ្លួន។
- ☐ ១០. ត្រូវទទួលបានការចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសំរេចលើជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន និង សង្គម។
- ☐ ១១. ត្រូវទទួលបាននូវឱកាស នូវផលប្រយោជន៍ពីភោគផលធម្មជាតិ និង នូវសេវាសាធារណៈដោយគ្មានរើសអើង។
- ☐ ១២. ត្រូវទទួលបានការធានា និង កិច្ចការពារសុវត្ថិភាព សន្តិសុខផ្ទាល់ខ្លួនពីសមត្ថកិច្ចគ្រប់ជាន់ថ្នាក់។

កម្មវិធីនេះផលិតដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

ហាមលក់

បោះពុម្ពផ្សាយ ឆ្នាំ ២០០៤